អគ្គិសនីកម្ពុជា
នាយកដ្ឋានមូលនិធិអគ្គិសនីតាមតំបន់ជនបទ
របាយការណ៍ប្រចាំឆ្នាំ២០២៤



ទឹកប្រាក់ឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី

- លំនៅឋាន ≤១0kWh/ខែ
- លំនៅឋាន ១១-៥0kWh/ខែ
- លំនៅឋាន ៥១-២00kWh/ខែ
- លំនៅឋាន >២00kWh/ខែ និងប្រភេទផ្សេងៗប្រើ <២00១kWh/ខែ
- សាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាព នៅជនបទ
- អតិថិជនក្នុងវិស័យកសិកម្មប្រើពេលយប់ (៩យប់-៧ព្រឹក)



សារពី
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា

ថាមពលអគ្គិសនី គឺជាតម្រូវការចាំបាច់បំផុតដែលមិនអាចខ្វះបានសម្រាប់មនុស្សជាតិនៅគ្រប់ទីកន្លែងក្នុងយុគសម័យថ្មីនេះ ជាពិសេសបច្ចេកវិទ្យាកាន់តែទំនើប ដែលធ្វើឱ្យការប្រើប្រាស់កាន់តែកើនឡើង ឥតឈប់ឈរសម្រាប់បម្រើជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង។

ចាប់ពីឆ្នាំ១៩៩៨ ប្រទេសកម្ពុជាយើងទទួលបានសុខសន្តិភាពពេញលេញទូទាំងប្រទេស ដោយសារគោលនយោបាយឈ្នះឈ្នះរបស់សម្តេចតេជោ វិស័យអគ្គិសនីក៏ដូចជាវិស័យផ្សេងៗទៀតបានចាប់ផ្តើមអភិវឌ្ឍមានលក្ខណៈទូលំទូលាយ។ ស្របពេលនេះ មូលនិធិអគ្គិសនីការបូនីយកម្មជនបទចាប់ផ្តើមដំណើរការដំបូងនៅឆ្នាំ២០០៤ ក្នុងគោលបំណងជំរុញ និងគាំទ្រឱ្យមានការផ្តត់ផ្គង់ដល់លំនៅឋានជនបទ និងដំហានបន្ទាប់បន្តយតម្លៃអគ្គិសនី ដែលក្នុងដំណាក់កាលនោះអត្រាថ្លៃអគ្គិសនីមានកម្រិតខ្ពស់ ហើយនៅតំបន់ជនបទខ្ពស់ជាងច្រើនដងធៀបនឹងនៅរាជធានីភ្នំពេញ ជាពិសេសតំបន់ដាច់ស្រយាលខ្លះដូចជា តំបន់កោះដែលមានអត្រាផ្តត់ផ្គង់ទាប ហើយនៅទូទាំងប្រទេសក្នុងឆ្នាំ២០០៨ មានតែ ១៧% ប៉ុណ្ណោះ។ ជាសមិទ្ធផល គឺចាប់តាំងពីឆ្នាំ២០១៦ អ្នកប្រើប្រាស់អគ្គិសនីពីបណ្តាញជាតិទូទាំងប្រទេសទទួលបានការឯកភាពថ្លៃដូចគ្នាទៅតាមប្រភេទនីមួយៗ ដែលរហូតមកដល់ពេលនេះប្រជាពលរដ្ឋរស់នៅតំបន់ជនបទក៏ដូចជាតាមបណ្តាទីប្រជុំជននៅក្នុងរាជធានី-ខេត្តបានទទួលអគ្គិសនីប្រើប្រាស់ដែលមានតម្លៃសមរម្យ ហើយអត្រាផ្តត់ផ្គង់នៅឆ្នាំ២០២៤ គឺកើនទៅដល់ ៩៥% ពីបណ្តាញជាតិដែលតម្លៃឯកភាពនេះទទួលបានពីការគាំទ្រយ៉ាងពេញទំហឹងពីរាជរដ្ឋាភិបាលតាមរយៈអគ្គិសនីកម្ពុជា ក្នុងការឧបត្ថម្ភធនទៅដល់អ្នកប្រើប្រាស់។

យើងខ្ញុំមានកិត្តិយសសូមបង្ហាញរបាយការណ៍ប្រចាំឆ្នាំរបស់នាយកដ្ឋានមូលនិធិអគ្គិសនីការបូនីយកម្មជនបទនៃអគ្គិសនីកម្ពុជាសម្រាប់ឆ្នាំ២០២៤ ដែលនាយកដ្ឋានបានទទួលថវិកាចំនួន ៥៣៧,៩០ ៣ន់លានរៀល សម្រាប់អនុវត្តបន្សាបថ្លៃលក់តាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលបានបង្កើតជាកម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទដែលបានជួយដល់បងប្អូនប្រជាពលរដ្ឋជាង ២លាន លំនៅឋានទូទាំងប្រទេស (ដែលមិនរាប់បញ្ចូលលំនៅឋានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា) ជាពិសេសតំបន់ដាច់ស្រយាលឱ្យទទួលបានការប្រើប្រាស់អគ្គិសនីមានថ្លៃដូចៗគ្នា។ កម្មវិធីផ្សេងៗដែលកំពុងអនុវត្តរួមមាន៖

១- ផ្តល់នូវកម្មវិធីឧបត្ថម្ភធនដើម្បីឱ្យតម្លៃអគ្គិសនីមានការឯកភាពទូទាំងប្រទេស ដែលក្នុងនោះបានឧបត្ថម្ភធនដល់ផ្នែក៖

- លំនៅឋានដែលប្រើចាប់ពី ១-១០គីឡូវ៉ាត់ម៉ោង/ខែ មានប្រមាណ ១,០០%។
- លំនៅឋានដែលប្រើចាប់ពី ១១-៥០គីឡូវ៉ាត់ម៉ោង/ខែ មានប្រមាណ ២៣,៨៨%។
- លំនៅឋានដែលប្រើចាប់ពី ៥១-២០០គីឡូវ៉ាត់ម៉ោង/ខែ មានប្រមាណ ៥០,៥៧%។
- លំនៅឋានដែលប្រើលើសពី ២០០គីឡូវ៉ាត់ម៉ោង/ខែ និងប្រភេទផ្សេងៗ ប្រើតិចជាង ២ ០០១គីឡូវ៉ាត់ម៉ោង/ខែ មានប្រមាណ ២១,៣៦%។
- សាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាព នៅជនបទមានប្រមាណ ០,៩៤%។

- អតិថិជនក្នុងវិស័យកសិកម្មប្រើពេលយប់ (ចាប់ពីម៉ោង ៩យប់-៧ព្រឹក) មានប្រមាណ ២,២៥%។

សរុបថវិការលើការឧបត្ថម្ភធនក្នុងឆ្នាំ២០២៤ មានចំនួនប្រមាណជាង ៥០០ ៣ន់លានរៀល ដែលរហូតតាំងពីកម្មវិធីនេះអនុវត្តនៅឆ្នាំ២០១៦ រហូតមកដល់បច្ចុប្បន្ន (ឆ្នាំ២០២៤) មានចំនួនប្រមាណជាង ៣ទ្រីលានរៀល។

២-ការផ្តល់សម្ភារអគ្គិសនីជាអំណោយដល់គ្រួសារមានជីវភាពខ្វះខាត ដែលពុំអាចមានលទ្ធភាពទិញសម្ភារបរិក្ខារដើម្បីភ្ជាប់ និងប្រើប្រាស់អគ្គិសនីបាន មានដូចជា ខ្សែចម្លងអគ្គិសនីពីនាឡិកាស្នង់ដល់ផ្ទះ អំពូលភ្លើង ឌីស្យុងទ័រ ប្រអប់ឌីស្យុងទ័រ កុងតាក់-ព្រឺ និងខ្សែចម្លងអគ្គិសនីក្នុងផ្ទះ បានចំនួន ១ ៦៤០ ខ្នងផ្ទះ នៅឆ្នាំ២០២៤ ដែលចំនួននេះបានកើនឡើងដល់ ៨៥ ១៦២ ខ្នងផ្ទះ តាំងពីកម្មវិធីដំបូង (ឆ្នាំ២០១២)។

៣-ការផ្តល់ប្រព័ន្ធផលិតថាមពលពីពន្លឺព្រះអាទិត្យ ជូនដល់គ្រួសារនៅតាមតំបន់ដែលពុំអាចសាងសង់ខ្សែបណ្តាញអគ្គិសនីទៅដល់ដូចជា តំបន់កូមិបណ្តែតទឹកក្នុងបឹងទន្លេសាប តំបន់កោះ និងតំបន់ជាច់ស្រយាល ដែលរួមមានប្រព័ន្ធកម្លាំង ៥០០វ៉ាត់ រួមជាមួយឆ្នាំងដាំបាយអគ្គិសនីចំណុះ៤លីត្រ មានចំនួន ៥៨៥ គ្រឿង និងប្រព័ន្ធពន្លឺព្រះអាទិត្យកម្លាំង ៥០វ៉ាត់ បានចំនួន ៦២៧ គ្រឿង។ ការផ្តល់ប្រព័ន្ធពន្លឺព្រះអាទិត្យតាមកម្លាំងផ្សេងៗ គឺមានចំនួនជាង ១២ម៉ឺន គ្រឿង តាំងពីកម្មវិធីចាប់ផ្តើម (ឆ្នាំ២០១២)។

៤-បានកែលម្អហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ដោយផ្តល់កម្ចីទុនជូនសៅការចំនួន ១៧ តំបន់អាជ្ញាបណ្ណ ដើម្បីកែលម្អប្រព័ន្ធបណ្តាញអគ្គិសនីទាំងតង់ស្យុងមធ្យម និងតង់ស្យុងទាប ប្រវែង ២៥៧,៣០ គីឡូម៉ែត្រ នាំឱ្យមានការផ្គត់ផ្គង់ចែកចាយរឹតតែមានលក្ខណៈប្រសើរឡើងចំនួន ២ ៨៨៥ គ្រួសារ។ គិតរហូតមកដល់ឆ្នាំ២០២៤ (ឆ្នាំ២០១៦-ឆ្នាំ២០២៤) ប្រព័ន្ធបណ្តាញអគ្គិសនីប្រវែង ១៥ ២៦៨ គីឡូម៉ែត្រ ត្រូវបានកែលម្អ។

៥-អនុគ្រោះថ្លៃអគ្គិសនីសម្រាប់អ្នកប្រើប្រាស់ប្រភេទកសិកម្ម ដោយផ្តល់នូវតម្លៃអនុគ្រោះពិសេស ៤៨០ រៀលក្នុង១គីឡូវ៉ាត់ម៉ោង ដល់អ្នកប្រើប្រាស់ក្នុងវិស័យកសិកម្មចាប់ពីម៉ោង ៩យប់-៧ព្រឹក បានចំនួន ១ ៥០៣ អតិថិជនថ្មីនៅឆ្នាំ២០២៤ ដែលកើនឡើងដល់ចំនួន ២ ៧៦៦ អតិថិជន ចាប់ពីកម្មវិធីបង្កើត (ឆ្នាំ២០១៦)។

ភាពជោគជ័យនេះ គឺទទួលបានពីការគាំទ្រ ចង្អុលបង្ហាញជាយុទ្ធសាស្ត្រពីរាជរដ្ឋាភិបាល ដែលមានចាប់តាំងពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងបន្តមក **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** តាមរយៈក្រសួងរ៉ែ និងថាមពល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការ ក៏ដូចជាស្ថាប័នពាក់ព័ន្ធ អាជ្ញាធរអគ្គិសនីកម្ពុជា សៅការទូទាំងប្រទេស និងដៃគូអភិវឌ្ឍន៍នានា ព្រមទាំងការខិតខំយ៉ាងសកម្មរបស់មន្ត្រីនិយោជិតយើងទាំងអស់គ្នា។ អគ្គិសនីកម្ពុជានឹងបន្តការគាំទ្រដល់ចក្ខុវិស័យ និងបេសកកម្មនេះ ដើម្បីបន្តផ្គត់ផ្គង់អគ្គិសនីទៅដល់បងប្អូនប្រជាពលរដ្ឋគ្រប់គ្រួសារមិនថារស់នៅទីណាក្នុងប្រទេសកម្ពុជារហូតដល់អត្រាចុងក្រោយនៃការផ្គត់ផ្គង់ជាអតិបរមា ពីបណ្តាញជាតិឱ្យទទួលបានការប្រើប្រាស់អគ្គិសនីមានស្ថិរភាព និងនិរន្តរភាព។

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា

អឿត. ច្រាំង ដួលសា

មាតិកា

		ទំព័រ
១	**សាវតារ**	**៤**
២	**គោលបំណង**	**៥**
៣	**បេសកកម្ម**	**៦**
៤	**ប្រភពមូលនិធិ និងការប្រើប្រាស់**	**៧**
៥	**កម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ**	**៨**
	៥.១ កម្មវិធីផ្តល់សម្ភារអគ្គិសនីជាអំណោយដល់គ្រួសារក្រីក្រ	៨
	៥.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ	១១
	៥.៣ កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ	១៣
	៥.៤ កម្មវិធីឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណដែលបានភ្ជាប់ប្រភពអគ្គិសនីពីបណ្តាញជាតិក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី តាមបណ្តារាជធានី-ខេត្ត	១៥
	៥.៥ កម្មវិធីផ្តល់ការអនុគ្រោះពិសេសក្នុងវិស័យកសិកម្ម	១៦

ឧបសម្ព័ន្ធ

១	របាយការណ៍សង្ខេបស្តីពីកម្មវិធីផ្តល់សម្ភារអគ្គិសនីជាអំណោយដល់គ្រួសារក្រីក្រក្នុងឆ្នាំ២០២៤	១៩
២	របាយការណ៍សង្ខេបស្តីពីកម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យក្នុងឆ្នាំ២០២៤	២១
៣	របាយការណ៍សង្ខេបស្តីពីកម្មវិធីជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ	២៣
៤	របាយការណ៍សង្ខេបស្តីពីកម្មវិធីឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីក្នុងឆ្នាំ២០២៤	២៧
៥	របាយការណ៍សង្ខេបស្តីពីកម្មវិធីផ្តល់ការអនុគ្រោះពិសេសក្នុងវិស័យកសិកម្មក្នុងឆ្នាំ២០២៤	៣០

១ សាថតារ

ប្រវត្តិ និងទិដ្ឋភាពច្បាប់នៃការបង្កើត ម.អ.ជ.

- ព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤៖
  - ម.អ.ជ. ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៤ តាមព្រះរាជក្រឹត្យខាងលើ ដើម្បីជំរុញការអភិវឌ្ឍអគ្គិសនីជនបទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
  - ម.អ.ជ. ជាស្ថាប័នសាធារណៈស្វយ័តមានលក្ខណៈសង្គមកិច្ច ហើយមានស្វ័យភាពក្នុងការគ្រប់គ្រងរដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុ និងដឹកនាំដោយក្រុមប្រឹក្សាភិបាល ម.អ.ជ. ចំនួន ១១រូប ជាតំណាងរបស់បណ្តាក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធនានា។
  - គោលបំណងនៃការបង្កើត ម.អ.ជ. គឺ ១-ជំរុញឱ្យមានសមធម៌ក្នុងការទទួលបានសេវាកម្មអគ្គិសនី ដោយជួយឱ្យប្រជាពលរដ្ឋនៅជនបទមានអគ្គិសនីប្រើប្រាស់តាមថ្លៃសមរម្យ រួមចំណែកកាត់បន្ថយភាពក្រីក្រ និង ២-ជំរុញ និងលើកទឹកចិត្តផ្នែកឯកជនឱ្យចូលរួមវិនិយោគធ្វើសេវាកម្មអគ្គិសនីនៅជនបទប្រកបដោយចីរភាព ជាពិសេសក្នុងការអនុវត្តបច្ចេកវិទ្យាថាមពលថ្មី និងថាមពលកកើតឡើងវិញ។
  - ប្រភពផ្តល់មូលនិធិដល់ ម.អ.ជ. រួមមាន៖ ១-អំណោយ និងជំនួយឥតសំណង ទទួលការឯកភាពពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ២-ប្រភពដទៃទៀតពីរាជរដ្ឋាភិបាលដែលមានលក្ខណៈទៀងទាត់។
- ព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៦៤ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មលើកទី១ លើព្រះរាជក្រឹត្យខាងលើដើម្បីកែសម្រួលសមាសភាពក្រុមប្រឹក្សាភិបាល ម.អ.ជ. ពីចំនួន ១១រូប ទៅ ១២រូប។
- ព្រះរាជក្រឹត្យលេខ នស/រកត/០៨១២/៧៣៤ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ ស្តីពីវិសោធនកម្មលើកទី២
  - ដាក់ ម.អ.ជ. ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា មានលក្ខណៈសង្គមកិច្ច និងមានគណនីដោយឡែក។ ម.អ.ជ. ត្រូវគ្រប់គ្រងដឹកនាំស្របតាមលក្ខន្តិកៈរបស់អគ្គិសនីកម្ពុជា។
  - ប្រភពមូលនិធិរបស់ ម.អ.ជ. រួមមាន៖ ១-កញ្ចប់ថវិកាសង្គមកិច្ចដែលបានគ្រោងក្នុងបញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា និងអំណោយដទៃទៀតរបស់អគ្គិសនីកម្ពុជា ២-អំណោយ និងជំនួយឥតសំណង ទទួលការឯកភាពពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ៣-ថវិកាពីរាជរដ្ឋាភិបាល។

២ គោលបំណង

ជំរុញឱ្យមានសមធម៌ក្នុងការទទួលសេវាកម្មអគ្គិសនី ដោយជួយឱ្យប្រជាជននៅជនបទបានទទួលអគ្គិសនីប្រើប្រាស់តាមថ្លៃដែលអាចជាវបានសម្រាប់សេដ្ឋកិច្ច សង្គម និងលំនៅឋាន ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ។

ជំរុញ និងលើកទឹកចិត្តផ្នែកឯកជនឱ្យចូលរួមវិនិយោគធ្វើសេវាកម្មអគ្គិសនីនៅតំបន់ជនបទ ប្រកបដោយចីរភាព ជាពិសេសក្នុងការអនុវត្តបច្ចេកវិទ្យាថ្មី និងថាមពលកកើតឡើងវិញដែលមានលក្ខណៈបច្ចេកទេស និងពាណិជ្ជកម្មសមស្រប។

៣ បេសកកម្ម

០១ ជំរុញវិសាលភាពការផ្គត់ផ្គង់អគ្គិសនីឱ្យដល់ប្រជាពលរដ្ឋនៅជនបទទូទាំងប្រទេស ទទួលបានអគ្គិសនីប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ស្ថិរភាព និងតម្លៃសមរម្យ ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង។

០២ ផ្តល់ការគាំទ្រដល់ការរៀបចំ និងអនុវត្តគម្រោងពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។

០៣ ផ្តល់ការគាំទ្រ និងជួយសម្រួលដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទអាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីបណ្តាញជាតិ ដោយការផ្តល់សម្ភារអគ្គិសនីជាអំណោយ។

០៤ ផ្តល់ការគាំទ្រ និងជួយសម្រួលឱ្យគ្រួសារជនបទ រស់នៅតំបន់ដាច់ស្រយាល ដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ អាចទទួលបានអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។

០៥ ផ្តល់ការគាំទ្រ និងផ្តល់កម្ចីទុនដល់អ្នកកាន់អាជ្ញាបណ្ណឯកជននៅតំបន់ជនបទ សម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីឱ្យពេញដែនអាជ្ញាបណ្ណចែកចាយរបស់ខ្លួន ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់គ្រួសារអាចភ្ជាប់ចរន្តអគ្គិសនីប្រើប្រាស់។

០៦ ផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណដែលបានភ្ជាប់ប្រភពអគ្គិសនីពីបណ្តាញជាតិ ក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីតាមបណ្តារាជធានី-ខេត្ត។

០៧ ផ្តល់ការគាំទ្រ និងជួយសម្រួលដល់អ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទ ក្នុងវិស័យកសិកម្មទទួលបានតម្លៃអនុគ្រោះពិសេស ៤៨០ រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ដល់ម៉ោង ៧:០០ព្រឹក។

០៨ ជំរុញការផ្គត់ផ្គង់អគ្គិសនីដោយថាមពលពន្លឺព្រះអាទិត្យ តាមតំបន់ដែលពុំអាចសាងសង់ខ្សែបណ្តាញអគ្គិសនីទៅដល់ដូចជា តំបន់ភូមិបណ្តែតទឹក តំបន់កោះ និងតំបន់ដាច់ស្រយាល។

៤ ប្រភពមូលនិធិ និងការប្រើប្រាស់

ប្រភពមូលនិធិដល់ ម.អ.ជ.[1] មានដូចខាងក្រោម៖

១. កញ្ចប់ថវិកាសង្គមកិច្ចដែលបានគ្រោងក្នុងបញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា និងអំណោយដទៃទៀតរបស់អគ្គិសនីកម្ពុជា។

២. អំណោយ និងជំនួយឥតសំណងដែលប្រភពនិងលក្ខខណ្ឌនៃការផ្តល់ត្រូវបានទទួលការឯកភាពពីក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣. ថវិកាពីរាជរដ្ឋាភិបាលកម្ពុជា។

ក្នុងឆ្នាំ២០២៤ ម.អ.ជ. ទទួលបានថវិកាពីអគ្គិសនីកម្ពុជា ចំនួន ៥៣១,៩៣ ប៊ីលានរៀល និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ចំនួន ៥,៩៧ ប៊ីលានរៀល សរុបចំនួន ចំនួន ៥៣៧,៩០ ប៊ីលានរៀល សម្រាប់អនុវត្តកម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ។ ថវិកាទទួលបានពីអគ្គិសនីកម្ពុជាសម្រាប់ចំណាយប្រតិបត្តិការរបស់ ម.អ.ជ. ផងដែរ។

ថវិកាទទួលបាននេះ ម.អ.ជ. បានយកទៅប្រើប្រាស់ក្នុងការអនុវត្តកម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ ដូចខាងក្រោម៖

១. កម្មវិធីផ្តល់សម្ភារអគ្គិសនីជាអំណោយដល់គ្រួសារក្រីក្រ។

២. កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ។

៣. កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។

៤. កម្មវិធីឧបត្ថម្ភធនប៉ះប៉ូវបង្ក្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណដែលបានភ្ជាប់ប្រភពអគ្គិសនីពីបណ្តាញជាតិ ក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី តាមបណ្តារាជធានី-ខេត្ត។

៥. កម្មវិធីផ្តល់តម្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ក្នុងវិស័យកសិកម្មដែលទទួលប្រភពផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិ។

ក្រាភិកបង្ហាញពីការប្រើប្រាស់ថវិកាតាមកម្មវិធីនីមួយៗ



[1] ព្រះរាជក្រឹត្យលេខ នស/រកត/០៨១២/៧៣៤ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ ស្តីពីវិសោធនកម្មលើមាត្រា២ មាត្រា៥ និងមាត្រា៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើត ម.អ.ជ. និងលើមាត្រា៤ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៦៤ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើត ម.អ.ជ.។

៥ កម្មវិធីរុញច្រៀងផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ

៥.១ កម្មវិធីផ្តល់សម្ភារអគ្គិសនីជាអំណោយដល់គ្រួសារក្រីក្រ

ម.អ.ជ. បានអនុវត្តកម្មវិធីនេះចាប់តាំងពីឆ្នាំ២០១២ រហូតមកដល់ឆ្នាំ២០២៤ ដោយបានផ្តល់សម្ភារអគ្គិសនីជាអំណោយ និងឧបត្ថម្ភជាថវិកា សរុបចំនួន ៧,៤៣ លានដុល្លារអាមេរិក ដើម្បីតភ្ជាប់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទបានចំនួន ៨៥ ១៦២ ខ្នងផ្ទះ។

តារាងសង្ខេបស្តីពីប្រភពថវិកា ចំនួនថវិកា និងចំនួនខ្នងផ្ទះបានតភ្ជាប់ចរន្តថ្មីពីឆ្នាំ២០១២ ដល់ឆ្នាំ២០២៤

ល.រ	ប្រភពថវិកា	ថវិកា (លានដុល្លារ)	ចំនួនខ្នងផ្ទះ
១	អគ្គិសនីកម្ពុជា	៣,៣៣	២១ ៨១០
២	ធនាគារពិភពលោក	២,២៥	៥០ ០០០
៣	ធនាគារអភិវឌ្ឍន៍អាស៊ី	១,០០	១០ ០០០
៤	ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់	០,៨៥	៣ ៣៥២
សរុប		**៧,៤៣**	**៨៥ ១៦២**

ក្រាកិកបង្ហាញពីលទ្ធផលនៃការអនុវត្តកម្មវិធីពីឆ្នាំ២០១២ ដល់ឆ្នាំ២០២៤



ក្នុងឆ្នាំ២០២៤ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ កម្មវិធីនេះបានជួយដល់ប្រជាជននៅតំបន់ជនបទចំនួន ១ ៦៤០ ខ្នងផ្ទះ ដែល ម.អ.ជ. ផ្តល់តាមរយៈសេវាកម្មដើម្បីតភ្ជាប់ចរន្តអគ្គិសនី ដល់គ្រួសារជនបទ ដែលបានជួយដល់ការបង្កើតមុខរបរ និងលើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំថ្ងៃកាន់តែប្រសើរឡើង។

តារាងសង្ខេបស្តីពីចំនួនខ្នងផ្ទះបានតភ្ជាប់ចរន្តថ្មីតាមបណ្តាខេត្ត ក្នុងឆ្នាំ២០២៤

ល.រ	ខេត្ត	តាមរយៈសេវាកម្ម	ចំនួនខ្នងផ្ទះបានតភ្ជាប់ចរន្តថ្មី	ចំនួនភូមិគ្រប់ដណ្តប់
១	កំពង់ធំ	១	២៦៤	២៦
២	កណ្តាល	១	៦៨	១៦
៣	ក្រចេះ	១	៣០០	១៤
៤	ព្រះវិហារ	១	១៥០	២៥
៥	ពោធិ៍សាត់	៣	៥៨៣	៣៩
៦	សៀមរាប	១	២៤៣	១០
៧	តាកែវ	១	៣២	៧
សរុប		**៩**	**១ ៦៤០**	**១៣៧**

តារាងសង្ខេបសម្ភារអគ្គិសនីដែលបានផ្តល់ជាអំណោយដល់គ្រួសារក្រីក្រ ឆ្នាំ២០២៤

ល.រ	បរិយាយ	ក្នុង១គ្រួសារ	សរុបសម្ភារអគ្គិសនី
១	ខ្សែចម្លងទង់ដែង (2x1.5mm²)	១៥ ម៉ែត្រ	២៤ ៦០០ ម៉ែត្រ
២	ឌីស្យុងទ័រក្នុងផ្ទះ២ប៉ូល (2P-10A)	១ កំប្លេរ	១ ៦៤០ កំប្លេរ
៣	ប្រអប់ឌីស្យុងទ័រ	១ កំប្លេរ	១ ៦៤០ កំប្លេរ
៤	កុងតាក់ និងឈ្នាប់ចរន្ត (ព្រី)	៣ គ្រាប់	៤ ៩២០ គ្រាប់
៥	កន្ទុយ (គូទ) អំពូល	៣ គ្រាប់	៤ ៩២០ កំប្លេរ
៦	អំពូលភ្លើង LED	៣ អំពូល	៤ ៩២០ អំពូល
៧	ខ្សែចម្លងអាលុយមីញ៉ូម (2x16mm²)	៨០ ម៉ែត្រ	១៣១ ២០០ ម៉ែត្រ
ចំនួនគ្រួសារក្រីក្របានទទួលផល ១ ៦៤០ គ្រួសារ			

ព័ត៌មានអំពីចំនួនខ្នងផ្ទះបានតភ្ជាប់ចរន្តថ្មីតាមបណ្តាខេត្ត និងភូមិគ្រប់ដណ្តប់មានបង្ហាញជូនក្នុង**ឧបសម្ព័ន្ធទី១**។

រូបភាពបង្ហាញពីអ្នកទទួលផលក្រោមកម្មវិធីផ្តល់សម្ភារអគ្គិសនីជាអំណោយ ដល់គ្រួសារក្រីក្រនៅខេត្តកំពង់ធំ[2]

រូបភាពនេះបានង្ហាញថា បន្ទាប់ពីចរន្តអគ្គិសនីពីបណ្តាញជាតិបានភ្ជាប់ ដល់លំនៅឋានរួចមក កុមារី សម្បត្តិ សុខហេង អាចមើលមេរៀន និងធ្វើកិច្ចការសាលានៅផ្ទះខ្លួនឯងបានរហូតដល់ពេលយប់។ ប្រភពថាមពលអគ្គិសនីដែលមានស្ថិរភាព បានផ្តល់នូវឱកាសដល់ក្រុមគ្រួសារជាច្រើនទៀតទូទាំងប្រទេសដូចក្រុមគ្រួសាររបស់សុខហេង ដែរ។

កម្មវិធីផ្តល់សម្ភារអគ្គិសនីជាអំណោយដល់គ្រួសារក្រីក្រនៅស្រុកសណ្តាន់ ខេត្តកំពង់ធំ។

ការពង្រីកបណ្តាញអគ្គិសនីទៅដល់តំបន់ដាច់ស្រយាល កាន់តែមានសារៈសំខាន់សម្រាប់អ្នកប្រើប្រាស់ដែលមានពិការភាព។ ដោយសារពិការភាពពីកំណើត លោក អុល ពិតជាពិបាកក្នុងការធ្វើចលនា ជាហេតុនាំអោយលោក ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរកប្រាក់ចំណូល ដើម្បីតភ្ជាប់ចរន្តអគ្គិសនី។

កម្មវិធីផ្តល់សម្ភារអគ្គិសនីជាអំណោយដល់គ្រួសារក្រីក្រនេះបានជួយសម្រួលលោក អុល ទទួលបានអគ្គិសនីប្រើប្រាស់ប្រចាំថ្ងៃនៅក្នុងផ្ទះរបស់លោក បានយ៉ាងល្អប្រសើរ។

កម្មវិធីផ្តល់សម្ភារអគ្គិសនីជាអំណោយដល់គ្រួសារក្រីក្រនៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។

[2] ដកស្រង់ចេញពីសៀវភៅ "មូលនិធិអគ្គិសនីកាវ៉ូបនីយកម្មជនបទ ២០ ឆ្នាំនៃការផ្សារភ្ជាប់ និង វឌ្ឍនភាព"

៥.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ

- **កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ**

កម្មវិធីនេះ ម.អ.ជ. បានអនុវត្តចាប់តាំងពីឆ្នាំ២០១២ រហូតមកដល់ឆ្នាំ២០២៤ ដោយបានឧបត្ថម្ភប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះដល់ប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាល ពុំទាន់មានអគ្គិសនីប្រើប្រាស់ បានចំនួន ១២១ ១០៦ ខ្នងផ្ទះ ដោយបានចំណាយថវិកាសរុបចំនួន ២៧,១៩ លានដុល្លារអាមេរិក។

តារាងសង្ខេបស្តីពីប្រភពថវិកា ចំនួនថវិកា និងចំនួនខ្នងផ្ទះ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០២៤

ល.រ	ប្រភពថវិកា	ថវិកា (លានដុល្លារ)	ចំនួនខ្នងផ្ទះ
១	អគ្គិសនីកម្ពុជា	១៩,៨៣	៨៦ ៦៩៥
២	ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់	៣,៥៧	២២ ៤១១
៣	ធនាគារពិភពលោក	៣,៧៩	១២ ០០០
សរុប		**២៧,១៩**	**១២១ ១០៦**

តារាងសង្ខេបស្តីពីប្រភពថវិកា ចំនួនថវិកា និងចំនួនខ្នងផ្ទះ ឆ្នាំ២០២៤

ល.រ	ប្រភពថវិកា	ថវិកា (ដុល្លារ)	ចំនួនខ្នងផ្ទះ
១	អគ្គិសនីកម្ពុជា	៣៨៧ ៥៦៨	៥៨៥
២	ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់	៦៥ ១៥៦	៦២៧
សរុប		**៤៥២ ៧២៤**	**១ ២១២**

របាយការណ៍សង្ខេបស្តីពីកម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី២**។

កម្មវិធីនេះបានជួយដល់ប្រជាជននៅតំបន់ជនបទចំនួន ១ ២១២ ខ្នងផ្ទះ បានទទួលអគ្គិសនីប្រើប្រាស់នៅតំបន់ដែលពុំអាចសាងសង់ខ្សែបណ្តាញអគ្គិសនីទៅដល់ ឬមានប្រសិទ្ធភាពទាបបំផុតដូចជា តំបន់កូមិបណ្តែតទឹកក្នុងបឹងទន្លេសាប តំបន់កោះ និងតំបន់ដាច់ស្រយាល។

ផែនទីបង្ហាញពីខេត្តបានដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ក្នុងឆ្នាំ២០២៤



រូបភាពបង្ហាញពីកម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះនៅស្រុកក្រគរ និងស្រុកកណ្តៀង ខេត្តពោធិ៍សាត់[3]

- **កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យបំភ្លឺសាធារណៈ**

វឌ្ឍនភាព និងសមិទ្ធផលកម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យបំភ្លឺសាធារណៈដែល ម.អ.ជ. បានផ្តល់ជាអំណោយជូនតាមវិស័យនានា ដើម្បីបម្រើជាផលប្រយោជន៍សាធារណៈ ក្នុងឆ្នាំ២០២៤ មានដូចខាងក្រោម៖

១. **វិស័យសាសនា-វប្បធម៌៖** ម.អ.ជ. បានផ្តល់ និងដំឡើងប្រព័ន្ធចំនួន ៣៤៨ កំប្លេរ ជាអំណោយសម្រាប់បំភ្លឺនៅតាមវត្តអារាម និងវិហារ-ស៊ូវ៉ាវ នៅតំបន់ជនបទ។

២. **វិស័យអប់រំ៖** ម.អ.ជ. បានផ្តល់ និងដំឡើងប្រព័ន្ធចំនួន ៧ កំប្លេរ ជាអំណោយសម្រាប់បំភ្លឺក្នុងបរិវេណសាលារៀន នៅតំបន់ដាច់ស្រយាល។

៣. **វិស័យរដ្ឋបាលសាធារណៈ៖** ម.អ.ជ. បានផ្តល់ និងដំឡើងប្រព័ន្ធចំនួន ២០២ កំប្លេរ ជាអំណោយសម្រាប់បំភ្លឺផ្លូវ និងអគាររដ្ឋបាលសាធារណៈនៅតាមបណ្តាឃុំ-ស្រុក នៅតំបន់ជនបទ។

[3] ដកស្រង់ចេញពីសៀវភៅ "មូលនិធិអគ្គិសនីកាវ៉ូបនីយកម្មជនបទ ២០ ឆ្នាំនៃការផ្សារភ្ជាប់ និង វឌ្ឍនភាព"

៥.៣ កម្មវិធីដួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ

ចាប់តាំងពីឆ្នាំ២០១២ ដល់ឆ្នាំ២០២៤ ម.អ.ជ. បានផ្តល់ថវិកាជួយទុនសម្រាប់ពង្រីក និងកែលម្អហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីនៅតំបន់ជនបទ ជូនសេវាករចំនួន ២៧៣ តំបន់អាជ្ញាបណ្ណ ដែលបានកែលម្អប្រព័ន្ធបណ្តាញអគ្គិសនីទាំង តង់ស្យុងមធ្យម និងតង់ស្យុងទាប សរុបប្រវែង ១៩ ០០៤ គីឡូម៉ែត្រ ដែលនាំឱ្យមានការផ្គត់ផ្គង់ចែកចាយតែតែមានលក្ខណៈប្រសើរឡើងចំនួន ៣២៧ ៣៧៦ ខ្នងផ្ទះ ក្នុងនោះបានផ្តល់ថវិកាកម្ចីទុនចំនួន ៩៥,០៨ លានដុល្លារអាមេរិក និងថវិកាជំនួយឥតសំណងចំនួន ១០,៥៧ លានដុល្លារអាមេរិក សរុបរួមចំនួន ១០៥,៦៥ លានដុល្លារអាមេរិក។

តារាងសង្ខេបស្តីពីប្រភពថវិកា ចំនួនថវិកា ចំនួនខ្នងផ្ទះ និងប្រវែងខ្សែបណ្តាញ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០២៤

ប្រភពថវិកា	ចំនួនគម្រោង	ប្រវែង (គីឡូម៉ែត្រ)	ចំនួនខ្នងផ្ទះ	ប្រាក់ជំនួយ (លានដុល្លារ)	ប្រាក់កម្ចី (លានដុល្លារ)
អគ្គិសនីកម្ពុជា	៨៥១	១៥ ៥៨៧	២៦៩ ១៤២	៨,១៨	៧៧,៩៣
ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់	១៧៣	៣ ៤១៧	៥៨ ២៣៤	២,៣៩	១៧,១៥
សរុប: ២៧៣ សេវាករ	**១ ០២៤**	**១៩ ០០៤**	**៣២៧ ៣៧៦**	**១០,៥៧**	**៩៥,០៨**

ក្នុងឆ្នាំ២០២៤ ម.អ.ជ. បានផ្តល់កម្ចីទុនវិនិយោគគ្មានការប្រាក់ផង និងជាអំណោយផង ក្នុងគោលបំណងជំរុញការផ្គត់ផ្គង់ថាមពលឱ្យដល់គ្រប់លំនៅឋានដល់សេវាករចំនួន ១៧ តំបន់អាជ្ញាបណ្ណ សម្រាប់សាងសង់ខ្សែបណ្តាញតង់ស្យុងមធ្យម (MV) និងតង់ស្យុងទាប (LV) បានប្រវែងសរុបចំនួន ២៥៧,៣០ គីឡូម៉ែត ក្នុងនោះខ្សែបណ្តាញប្រវែង ២១៣,៥០ គីឡូម៉ែត ប្រើប្រាស់ថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងខ្សែបណ្តាញប្រវែង ៤៣,៨០ គីឡូម៉ែត ប្រើប្រាស់ថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់។

តារាងសង្ខេបស្តីពីប្រភពថវិកា ចំនួនថវិកា ចំនួនខ្នងផ្ទះ និងប្រវែងខ្សែបណ្តាញ ក្នុងឆ្នាំ២០២៤

ប្រភពថវិកា	ចំនួនគម្រោង	ប្រវែង (គីឡូម៉ែត្រ)	ចំនួនខ្នងផ្ទះ	ប្រាក់ជំនួយ (លានដុល្លារ)	ប្រាក់កម្ចី (លានដុល្លារ)
អគ្គិសនីកម្ពុជា	១១	២១៣,៥០	១ ៨២០	០,៣០	១,០៣
ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់	៧	៤៣,៨០	១ ០៦៥	០,០៩	០,២៨
សរុប: ១៧ សេវាករ	**១៨**	**២៥៧,៣០**	**២ ៨៨៥**	**០,៣៩**	**១,៣១**

កម្មវិធីនេះបានជួយជំរុញដល់សហគ្រាសអគ្គិសនីជនបទ ក្នុងការពង្រីកវិសាលភាពផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់អាជ្ញាបណ្ណរបស់ខ្លួនឱ្យបានពេញលេញ ផ្គត់ផ្គង់ដល់សហគមន៍ និងគ្រួសារជនបទកាន់តែច្រើនអាចទទួលបាននូវសេវាកម្មផ្គត់ផ្គង់អគ្គិសនី ដែលមានគុណភាពពីប្រព័ន្ធបណ្តាញសហគ្រាសអគ្គិសនីជនបទ។

របាយការណ៍សង្ខេបស្តីពីកម្មវិធីជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២៤ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី៣**។

រូបភាពបង្ហាញពីអ្នកទទួលផលក្រោមកម្មវិធីជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ[4]

តារាងសង្ខេបស្តីពីប្រវែងខ្សែបណ្តាញបានសាងសង់រួច និងចំនួនកូមិតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្នុងឆ្នាំ២០២៤

ល.រ	ខេត្ត	ចំនួនសៀវភៅដែលទទួលបាន	ប្រវែងខ្សែបណ្តាញបានសាងសង់រួច (គីឡូម៉ែត)		ចំនួនកូមិគ្របដណ្តប់
			តង់ស្យុងទាប	តង់ស្យុងមធ្យម	
ក ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា					
១	បន្ទាយមានជ័យ	១	១,១២	៤,១៥	៤
២	បាត់ដំបង	១	១៨,៩០	១៧,៣០	៣
៣	កំពង់ចាម	២	៥,៤២	៣,៤៥	៦
៤	កំពង់ធំ	១	២,៣៥	២,៧៦	៤
៥	កំពត	១	៩,៥៥	២,៤០	៧
៦	ក្រចេះ	១	២៨,១០	២១,០០	១១
៧	ពោធិ៍សាត់	២	២១,២០	១៤,៤០	៦
៨	សៀមរាប	១	៨,៧០	១៦,៩០	៣
៩	តាកែវ	១	១៦,៨៥	៧,៦៥	៣០
១០	ឧត្តរមានជ័យ	១	៩,៨០	១,៥០	៣
សរុប ក		**១២**	**១២១,៩៩**	**៩១,៥១**	**៧៧**
			២១៣,៥០		
ខ ក្រោមថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់					
១	បាត់ដំបង	១	៣,៧៥	០,៧០	៦
២	កំពង់ធំ	១	៣,៧០	៤,២០	៥
៣	ព្រះវិហារ	១	៤,៥៤	២,០០	១
៤	ព្រៃវែង	១	២,០១	០,៥០	៥
៥	ពោធិ៍សាត់	៣	១៥,១០	៧,៣០	២៩
សរុប ខ		**៧**	**២៩,១០**	**១៤,៧០**	**៤៦**
			៤៣,៨០		**៤៦**
សរុប ក+ខ		**១៩**	**១៥១,០៩**	**១០៦,២១**	**១២៣**
			២៥៧,៣០		

[4] ដកស្រង់ចេញពីសៀវភៅ "មូលនិធិអគ្គិសនីកាវ៉ូបនីយកម្មជនបទ ២០ ឆ្នាំនៃការផ្សារភ្ជាប់ និង វឌ្ឍនភាព"

៥.៤ កម្មវិធីឧបត្ថម្ភធនប៉ះប៉ូវបង្ក្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណដែលបានភ្ជាប់ប្រភពអគ្គិសនីពីបណ្តាញជាតិ ក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី តាមបណ្តាអាជ្ញាធរ-ខេត្ត

ម.អ.ជ. បានអនុវត្តកម្មវិធីនេះចាប់តាំងពីឆ្នាំ២០១៦ រហូតមកដល់ឆ្នាំ២០២៤ ដោយបានផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្ក្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណចំនួន ៤០១ សៅរ៉ា នូវថវិកាសរុបចំនួន ៨០៨ លានដុល្លារអាមេរិក ដើម្បីឱ្យតម្លៃអគ្គិសនីមានការឯកភាពទូទាំងប្រទេសដល់អតិថិជនចំនួន ២,២៧ លានលំនៅឋាន (ដែលមិនរាប់បញ្ចូលលំនៅឋានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា) ស្មើនឹងបរិមាណថាមពលចំនួន ១៣ ១២៩ លាន គីឡូវ៉ាត់ម៉ោង។

ក្នុងឆ្នាំ២០២៤ ម.អ.ជ. ផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្ក្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់នៅតំបន់ជនបទ និងអាជីវកររលក់ដូរនៅផ្សារ ដូចខាងក្រោម៖

ក្រាភិកបង្ហាញពីអត្រាឧបត្ថម្ភធនប៉ះប៉ូវបង្ក្រប់ថ្លៃលក់អគ្គិសនី



ក្រាភិកបង្ហាញពីអត្រាឧបត្ថម្ភធនប៉ះប៉ូវបង្ក្រប់ថ្លៃលក់អគ្គិសនី
សម្រាប់តំបន់អាជ្ញាបណ្ណដែលមានអត្រាថ្លៃពិតស្មើនឹង ១ ០០០ រៀល



របាយការណ៍សង្ខេបស្តីពីកម្មវិធីឧបត្ថម្ភធនប៉ះប៉ូវបង្ក្រប់ថ្លៃលក់អគ្គិសនីក្នុងឆ្នាំ២០២៤ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី៤**។

៥.៥ កម្មវិធីផ្តល់ការអនុគ្រោះពិសេសក្នុងវិស័យកសិកម្ម

៥.៥.១ ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម

ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២១ ក្រសួងរ៉ែ និងថាមពល បានដាក់ចេញនូវគោលនយោបាយផ្តល់ថ្លៃអនុគ្រោះពិសេសចំពោះអ្នកប្រើប្រាស់ដែលយកអគ្គិសនីទៅបូមទឹកសម្រាប់ការធ្វើកសិកម្មនៅពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ឱ្យបង់ថ្លៃអគ្គិសនីត្រឹមតែ ៤៨០ រៀល ក្នុង១គីឡូវ៉ាត់ម៉ោង។ ដើម្បីជំរុញការអនុវត្តកម្មវិធីនេះ ម.អ.ជ. បានសាងសង់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីក្នុងតំបន់របស់សេវាករ ក្រោមថវិការបស់អគ្គិសនីកម្ពុជា តាមបណ្តាខេត្តគោលដៅចំនួន ៧ ខេត្ត មានដូចខាងក្រោម៖

ល.រ	ខេត្ត	ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីសាងសង់រួច ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២១					
		គីឡូម៉ែត្រ		កំប្លែ		អតិថិជន	ថវិកា
		MV	LV	Tr	TOU	នាក់	USD
១	បន្ទាយមានជ័យ	២៦,៥១	២៩,០០	១៤	៤	៦	៤៩៤ ២៩២
២	បាត់ដំបង	៤២,០០	៤៩,០០	២២	២២	១	៧៧៦ ៥៨៧
៣	កំពង់ចាម	១,៤៥	១,៤៥	២	-	-	៣៣ ៣១៦
៤	កំពង់ធំ	៤៤,៨៣	៥២,៧៦	២០	១២	៣	៨២៤ ២៨២
៥	កណ្តាល	៥,៤៨	៧,០០	៤	៧	២	១២៤ ២៤៩
៦	ព្រៃវែង	២៨,៩៧	៣៩,៨០	១៨	១៥៥	១៥៥	៧២៥ ៤៧៥
៧	ពោធិ៍សាត់	១១៣,០៦	១៦៥,៤៨	៦៩	៦៩	២	២ ៤៣៦ ៩៣០
សរុប		**២៦២,៣០**	**៣៤៤,៤៩**	**១៤៩**	**២៦៩**	**១៦៩**	**៥ ៤១៥ ១៣១**

៥.៥.២ ការផ្តល់ថ្លៃអនុគ្រោះពិសេសចំពោះអ្នកប្រើប្រាស់អគ្គិសនីក្នុងវិស័យកសិកម្ម

ចាប់ពីឆ្នាំ២០២២ ក្រសួងរ៉ែ និងថាមពល បានពង្រីកវិសាលភាពនៃការផ្តល់ថ្លៃអនុគ្រោះពិសេសចំពោះអ្នកប្រើប្រាស់អគ្គិសនីក្នុងវិស័យកសិកម្មនៅពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ឱ្យបង់ថ្លៃអគ្គិសនីត្រឹមតែ ៤៨០ រៀល ក្នុង១គីឡូវ៉ាត់ម៉ោង។

ចាប់ពីថ្ងៃយុទ្ធនាការក្នុងខែវិច្ឆិកា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ការផ្តល់ថ្លៃអនុគ្រោះពិសេសចំពោះអ្នកប្រើប្រាស់អគ្គិសនីក្នុងវិស័យកសិកម្មមានចំនួន ២ ៧៦៦ អតិថិជន។

តារាងសង្ខេបស្តីពីចំនួនអតិថិជនក្នុងវិស័យកសិកម្មបានតភ្ជាប់ចរន្តអគ្គិសនី ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៤

តំបន់អាជ្ញាបណ្ណ	ចំនួនអតិថិជន		សរុប
	អតិថិជនប្តូរមកប្រើតម្លៃអនុគ្រោះ	អតិថិជនថ្មី	
អគ្គិសនីកម្ពុជា	២៦២	៩១	៣៥៣
អ្នកកាន់អាជ្ញាបណ្ណ	១ ២២៣	១ ១៩០	២ ៤១៣
សរុប	**១ ៤៨៥**	**១ ២៨១**	**២ ៧៦៦**

ក្នុងឆ្នាំ២០២៤ កម្មវិធីនេះបន្តផ្តល់តម្លៃអនុគ្រោះពិសេស ៤៨០ រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់អ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទក្នុងវិស័យកសិកម្ម សម្រាប់ការប្រើប្រាស់ពេលយប់ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីដែលទទួលប្រភពពីបណ្តាញជាតិ ទាំងស្ថិតនៅក្រោមតំបន់អគ្គិសនីកម្ពុជា និងក្រោមតំបន់អ្នកកាន់អាជ្ញាបណ្ណ។

តារាងសង្ខេបស្តីពីចំនួនអតិថិជនគ្រប់ប្រភេទក្នុងវិស័យកសិកម្មបានតភ្ជាប់ចរន្តអគ្គិសនី ក្នុងឆ្នាំ២០២៤

តំបន់អាជ្ញាបណ្ណ	ចំនួនអតិថិជន			ប្រភេទអតិថិជន
	អតិថិជនប្តូរមកប្រើតម្លៃអនុគ្រោះ	អតិថិជនថ្មី	សរុប	
អគ្គិសនីកម្ពុជា	៤៧	៦៦	**១១៣**	- រោងម៉ាស៊ីន ១៧ - ចិញ្ចឹមសត្វ ៩ - ដាំដុះ ៨៧
អ្នកកាន់អាជ្ញាបណ្ណ	៣៦៤	១ ០២៦	**១ ៣៩០**	- រោងម៉ាស៊ីន ២០ - ចិញ្ចឹមសត្វ ៨៤ - ដាំដុះ ១ ២៨៦
សរុប	**៤១១**	**១ ០៩២**	**១ ៥០៣**	-

កម្មវិធីនេះជាចលករដ៏សំខាន់ជំរុញដល់វិស័យកសិកម្ម ដោយគាំទ្រដល់សកម្មភាពដូចជា ការដាំដុះដំណាំ ការចិញ្ចឹមសត្វ វារីវប្បកម្ម ការសម្ងួត ការបង្កក ការផលិតជី ការកិនស្រូវ ការកែច្នៃចំណីអាហារ និងភេសជ្ជៈ និងការផលិតចំណីសត្វ។ គ្រួសារជនបទ អាជីវករ កសិករ ជាច្រើនបានទទួលអត្ថប្រយោជន៍ពីកម្មវិធីនេះ។

រូបភាពបង្ហាញពីអតិថិជនទទួលបានតម្លៃអនុគ្រោះពិសេសសម្រាប់ការប្រើប្រាស់ពេលយប់ក្នុងវិស័យកសិកម្ម[5]

របាយការណ៍សង្ខេបស្តីពីកម្មវិធីផ្តល់តម្លៃអនុគ្រោះពិសេស ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ក្នុងវិស័យកសិកម្ម ក្នុងឆ្នាំ២០២៤ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី៥**។

[5] ដកស្រង់ចេញពីសៀវភៅ "មូលនិធិអគ្គិសនីកាវ៉ូបនីយកម្មជនបទ ២០ ឆ្នាំនៃការផ្សោរភ្ជាប់ និង វឌ្ឍនភាព"

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១
រចាយការណ៍សង្ខេបស្តីពីកម្មវិធីផ្តល់សម្ភារអគ្គិសនីដល់គ្រួសារក្រីក្រក្នុងឆ្នាំ២០២៤
ព័ត៌មានសង្ខេបស្តីពីចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តអគ្គិសនីថ្មី
និងទីតាំងខេត្ត ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា

លរ	ខេត្ត/រាជធានី	ភូមិ	ឃុំ	ស្រុក	ចំនួនខ្នងផ្ទះ	លេខ អ.ប	អ្នកកាន់អាជ្ញាបណ្ណ
១	កំពង់ធំ	ភូមិក្រាំ ភូមិរូង ភូមិព្រៃលាប ភូមិស្លាកែត ភូមិពង្រលឹង ភូមិលាវ ភូមិកំពង់ស្តេច ភូមិចារ	ក្រាំ	បារាយណ៍	២៦៤	៣៦៧អ	លោក សឿន សុផល (គម្រោងទី៤)
		ភូមិវាលស្តារ ភូមិតាពៅ ភូមិត្រពាំងសង្កែ ភូមិពោន ភូមិវាលធំ ភូមិអន្លង់ថ្ម ភូមិទូកពីរ	គគីរធំ				
		ភូមិត្រដែត ភូមិប្រនាគ ភូមិពណ្ណរាយ ភូមិបឹង ភូមិពន្លៃ ភូមិពងទឹក ភូមិចើងដើង ភូមិតាអោង	ចើងដើង				
		ភូមិត្រពាំងទូកភូមិបាក់ស្នាក្រោមភូមិអូរចំរេះ	បាក់ស្នា				
២	កណ្តាល	ភូមិកណ្តាល ភូមិកំពង់ពោធិ៍ ភូមិតាគល់ ភូមិកំពង់ពោធិ៍ត្បូង ភូមិគរ ភូមិចេក ភូមិទួលក្រាំង ភូមិទួលក្រូច ភូមិធំ ភូមិវិហារ ភូមិស្វាយដំណាក់ ភូមិសំរោង ភូមិអង្គ ភូមិអម្ពិលលាស់ ភូមិអំពិល	ក្រាំងយ៉ូវ	ស្អាង	៦៨	១៧៩អ	សហគ្រាសអគ្គិសនីញ៉ឹក ម៉ី* (គម្រោងទី២)
		ភូមិព្រែករាំង	ទឹកវិល				
៣	ក្រចេះ	ភូមិចង្កូប ភូមិអូរតាណឹង ភូមិស្រែស្បូវ	ក្បាលដំរី	អូរគ្រៀងសែនជ័យ	៣០០	៣៤៦អ	ក្រុមហ៊ុន ជា សុខខេង (គម្រោងទី២)
		ភូមិអូរគ្រៀង ភូមិទួលទ្រាំង	អូរគ្រៀង				
		ភូមិស្រែរលួស ភូមិស្រែឈូក ភូមិប៉ាក្លែ ភូមិស្រែត្នោត	រលួសមានជ័យ				
		ភូមិស្រែជិះ ភូមិរវៀង	ស្រែជិះ				
		ភូមិស្វាយចេក ភូមិដើងពាត ភូមិបាយសំណុំ	កោះខ្សែរ	សំបូរ			
៤	ព្រះវិហារ	ភូមិកេរ្តិ៍ ភូមិខ្នារ ភូមិព្រៃស្នួល ភូមិសំរិត	រតនៈ	រវៀង	១៥០	១២៨អ	សហគ្រាសអៀង ខន អេឡិកទ្រីស៊ីធី អានុភាពតំបន់ភ្នំលាក់កេរ
		ភូមិចំបក់ផ្អែម ភូមិដំណាក់ចិន ភូមិតាតុង ភូមិត្រពាំងឫស្សី	រស្មី				
		ភូមិឈ្នួន ភូមិទន្លាប់ ភូមិឫស្សីស្រុក	រួសរាន់				
		ភូមិដូង ភូមិបុស្ស	រីករាយ				
		ភូមិតាំងត្រក ភូមិត្នោតម្ល ភូមិបាក់ក្តោង ភូមិបឹង ភូមិរវៀងជើង ភូមិរវៀងត្បូង ភូមិអូរ	របៀប				
		ភូមិត្រពាំងផ្ចឹក ភូមិថ្នល់កែង ភូមិបុះពៃ ភូមិស្រែធំ	រុងរឿង				
		ភូមិអន្លង់ស្វាយ	រហ័ស				

៥	ពោធិ៍សាត់	ភូមិកណ្តាលភូមិកប៉ាស់ ភូមិកប៉ាស់លើ ភូមិក្បាលទាហាន ភូមិចាមចាស់ ភូមិចាមថ្មី ភូមិឈើទេព ភូមិដង្កៀបក្តាម ភូមិទៀនព្រៃ ភូមិទួលត្បែង ភូមិបំណក់ ភូមិផ្ទះចេក	ឈើតុំ	ក្រគរ	៣០០	៣៨៣អ	លោកស្រី ឃឹម ហៀង (គម្រោងទី២)
		ភូមិអន្សាចំបក់ ភូមិកំរ៉ែង ភូមិត្រពាំងស្នួល ភូមិអូចាន់ ភូមិបឹងស្មុក ភូមិទួលអណ្តែត	ស្វាយស				
		ភូមិចរ១ ភូមិកណ្តាល	ថ្មដា	វាលវែង	១៩	៣៩៦អ	លោកស្រី ប៉ែ សុបញ្ញា
		ភូមិក្រពើពីរលើ ភូមិក្រពើពីរក្រោម ភូមិស្មែត ភូមិចំការចេក ភូមិចំការគរ ភូមិក្រសាំងភ្នៅ ភូមិសំឡាញ ភូមិអូរតាទិន ភូមិថ្មសំលៀង ភូមិក្បាឆ្កែ ភូមិអូររាំវង់ ភូមិកតាអោន ភូមិកំប៉ង ភូមិដាអេិល	ក្រពើពីរ	វាលវែង	២៦៤	៤០៤អ	លោក ហេង ចន្ថារី*
		ភូមិច្រកព្រាល ភូមិអូរដំណាក់កន្សែង ភូមិតក់ឡក់ ភូមិតាំងយ៉ង់ ភូមិស្នឹងថ្មី	ប្រម៉ោយ				
៦	សៀមរាប	ភូមិកន្ធូត ភូមិក្រមុំបូល ភូមិជប់រំដេង ភូមិធ្នឹកជ្រុំ ភូមិពពេល ភូមិព្រៃល្វៀង ភូមិរុងរឿង ភូមិអន្លង់ត្បាល់ ភូមិអភិវឌ្ឍន៍ ភូមិអូរអាចៃ	កន្ធូត	ស្វាយលើ	២៤៣	៤០៦អ	លោកស្រី លឿង ស៊ីថា
៧	តាកែវ	ភូមិអង្គស្វាយចេក	ចារ	ព្រៃកប្បាស	៣២	១៧៩អ	សហគ្រាសអគ្គិសនីញ៉ឹក ម៉ី* (គម្រោងទី២)
		ភូមិកណ្តាលភូមិចេក ភូមិតានន ភូមិយុថ្កា ភូមិប្រមូលសុខ ភូមិស្វាយខម	ដូង	បាទី			
សរុប I		**១៣៧ ភូមិ**	**២៦ ឃុំ**	**១០ ស្រុក**	**១ ៦៤០**		

សំគាល់៖ * តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន២ ** តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន៣។



ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីផ្តល់សម្ភារអគ្គិសនីដល់គ្រួសារក្រីក្រក្នុងឆ្នាំ២០២៤

ដំណរភ្ជាប់ ដើម្បីចូលទៅកាន់ទីតាំង បែបឌីជីថល

ឧបសម្ព័ន្ធទី២
ស្តីពីកម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យក្នុងឆ្នាំ២០២៤

ទីតាំងដែលបានដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងក្រោមថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្នុងឆ្នាំ២០២៤

ល.រ	ខេត្ត	ស្រុក	ឃុំ	ចំនួនភូមិបានទទួលអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ
ក. ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា				
១	ពោធិ៍សាត់	ក្រគរ	ស្នោតជុំ	ភូមិចំបក់ធំ ភូមិបឹងវាល ភូមិព្រៃខ្លា ភូមិត្បែងជ្រុំ ភូមិសែនពេន ភូមិត្រាំ ភូមិឈើទាល ភូមិថ្មី ភូមិបង្គង់ឃ្មុំ ភូមិដំបូក១០០ ភូមិក្របីស ភូមិដំរម្ដាន
			បឹងកន្ធត	ភូមិកណ្តារេស ភូមិជដក ភូមិតាកែវក្រោម ភូមិត្រពាំងកន្ធត ភូមិត្រពាំងឃ្លៃ ភូមិថ្មី ភូមិឆ្លាម្ដម ភូមិបឹង ភូមិពោធិ៍ឃឿន ភូមិពោធិ៍អង្រ្កង ភូមិអូរអញ្ចាញ
			ក្បាលត្រាច	ភូមិឈើទាលខ្ពស់ ភូមិក្រឡាញ់ ភូមិត្រពាំងរំដេញ
			កំពង់លួង	ភូមិទី១ ភូមិទី២ ភូមិទី៣ ភូមិទី៤ ភូមិទី៥
			កំពង់ពោធិ៍	ភូមិកំពង់ឡ
			អូរសណ្តាន់	ភូមិចុងខ្ពង ភូមិក្រាំងធំ
			អន្សារចំបក់	ភូមិក្បាលដំរី
			ឈើតុំ	ភូមិចាមថ្មី ភូមិដង្កៀបក្តាម ភូមិទៀនព្រៃ ភូមិកប៉ាស់លើ
			អន្លង់ស្នោត	ភូមិខ្លាក្រពើ
		ភ្នំក្រវ៉ាញ	បាក់ចិញ្ចៀន	ភូមិកំពង់ខ្នុម ភូមិក្របៅជ្រុំ ភូមិចាន់សេរី ភូមិដំណាក់អំពិល ភូមិទួលពង្រ ភូមិបាក់ចិញ្ចៀន ភូមិស្រែជង ភូមិអូររំចង់ ភូមិអូរឫស្សី
			លាច	ភូមិស្បូវរីក ភូមិប៉ែន ភូមិបោះពួយ ភូមិក្រូចឆ្មា ភូមិលាច ភូមិពេជបាន ភូមិតានុក
			ព្រងិល	ភូមិស្វាយប៉ាក ភូមិសាយ ភូមិព្រងិល ភូមិអូរបាក់ត្រា ភូមិសំរោងយា ភូមិកំពែង
			រកាត	ភូមិព្រៃខ្ពង ភូមិមល់ ភូមិព្រៃស្មាច់
			សន្ទ្រែ	ភូមិក្បែត្របូរី ភូមិស្រែពពាយ ភូមិសន្ទ្រែ ភូមិគល់ទទឹង
			សំរោង	ភូមិអង្រ្កង ភូមិព្រែក១ ភូមិព្រែក២ ភូមិព្រែក៣ ភូមិសំរោង១ ភូមិវាល ភូមិសំរោង២ ភូមិអូរហោង ភូមិរវៀង
		បាកាន	ត្រពាំងជង	ភូមិកោះស្វាយ ភូមិត្រពាំងជង ភូមិក្តីឈ្នួល ភូមិអូររំចេក ភូមិពោធិ៍ល្សុំ ភូមិចំការអូរ ភូមិពិតត្រង់ ភូមិកោះកែវ ភូមិកាប់ក្រឡាញ់ ភូមិព្រះចំបក់ ភូមិក្រោលក្របី
			បឹងបត់កណ្តោល	ភូមិត្រាំសេះ ភូមិបត់កណ្តោល ភូមិបឹងឈូក ភូមិទួលឆ្នា ភូមិឫស្សីតាម៉ាន់ ភូមិស្វាយ ភូមិស្វាយជ្រុំ ភូមិដូងជ្រុំ ភូមិព្រះអំពិល ភូមិអូរ ភូមិបត់ត្រាច
			បឹងខ្នារ	ភូមិបឹងខ្នារ ភូមិដើមច្រេស ភូមិត្រាចក្រោល ភូមិវត្តជ្រៃ ភូមិព្រះម្ល
			ខ្នារទទឹង	ភូមិខ្នារទទឹង ភូមិផ្ទះស្លា ភូមិដំណាក់ធ្នង់ ភូមិបឹងឈូក ភូមិបាក់មែក

			មេទឹក	ភូមិជីរនាត ភូមិក្អមសំណ ភូមិប៉ោឡោ ភូមិព្រែកក្រ ភូមិក្តាត ភូមិត្រាង ភូមិចាយ៉ូវ ភូមិមេទឹក ភូមិតាមុំ ភូមិកោះខ្សាច់
		កណ្តៀង	រាំងទិល	ភូមិរាំងទិល
			វាល	ភូមិប្រឡាយធំ
			កណ្តៀង	ភូមិស្តានីយ៍
			កញ្ជរ	ភូមិត្បែងបង្គាប ភូមិកណ្តាល ភូមិទួលទទឹង ភូមិរលាំង ភូមិសំរោង
		ពោធិ៍សាត់	លលកសរ	ភូមិព្រែកស្តី
			បន្ទាយដី	ភូមិឥស្លាម
			រលាប	ភូមិអូរត្រាវ ភូមិព្រែកឆ្នោត ភូមិរលាប
		តាលោសែនជ័យ	ផ្ទះរុង	ភូមិប្តុកដង្កោរ
សរុប ក	**១ខេត្ត**	**៦ស្រុក**	**២៨ឃុំ**	**១៣៤ភូមិ**
ខ. ក្រោមថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់				
១	ពោធិ៍សាត់	តាលោសែនជ័យ	ផ្ទះរុង	ភូមិផ្ទះរុង ភូមិកណ្តាល ភូមិបត់រំដួល ភូមិកោះស្វាយ ភូមិតាសាល់ ភូមិក្រញ៉ាំ ភូមិដំណាក់កន្សែង ភូមិព្រែកន្លង់ ភូមិស្តុកខ្ពុំ ភូមិជង្រុក ភូមិជ្រៃក្រឹម ភូមិប្តុកដង្កោរ
			តាលោ	ភូមិគោករលំ ភូមិទួលទទឹង ភូមិទួលឬ ភូមិបួច្រេស ភូមិព្រៃរោង ភូមិថ្មី ភូមិតាលោ ភូមិទួលជ្រៅ ភូមិព្រៃតោ ភូមិបឹងកក់ ភូមិព្រៃវាំង ភូមិសិរីគន្ធា ភូមិត្រយ៉ងស ភូមិឆ្នាល់មាន់ ភូមិព្រៃកន្ធួត ភូមិតាំងគោក ភូមិបោសគរ ភូមិប្រហាលទិល ភូមិសំសាន្ត ភូមិកោះស្វាយ ភូមិកោះវត្ត
សរុប ខ	**១ខេត្ត**	**១ស្រុក**	**២ឃុំ**	**៣៣ភូមិ**
សរុប ក+ខ	**២ខេត្ត**	**៧ស្រុក**	**៣០ឃុំ**	**១៦៧ភូមិ**

សំគាល់៖ ក្នុងចំណោម ១៦៧ភូមិ មាន ១ភូមិ បានអនុវត្តក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ត្រួតគ្នា។

ឧបសម្ព័ន្ធទី៣
របាយការណ៍សង្ខេបស្តីពីកម្មវិធីជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនី
នៅតំបន់ជនបទ ក្នុងឆ្នាំ២០២៤
ព័ត៌មានសង្ខេបស្តីពីប្រវែងខ្សែបណ្តាញបានសាងសង់រួច និងទីតាំងតាមខេត្តនីមួយៗ

លរ	ខេត្ត/រាជធានី	ភូមិ	ឃុំ	ស្រុក	ប្រវែងខ្សែបណ្តាញបានសាងសង់រួច (គីឡូម៉ែត្រ)		លេខ អ.ប	អ្នកកាន់អាជ្ញាបណ្ណ
					តង់ស្យង់ទាប	តង់ស្យង់មធ្យម		
ក. ក្រោមឋិកាផ្តល់ដោយអគ្គិសនីកម្ពុជា								
១	បន្ទាយមានជ័យ	ភូមិស្រះដីក	ស្រះដីក	ភ្នំស្រុក	១,១២	៤,១៥	០៨១អ	លោក មួន ហាន (គម្រោងទី៧)
		ភូមិពន្លៃ ភូមិកំពីងពួយ	ភ្នំដី					
		ភូមិពោគ	ស្ពានស្រែង					
២	បាត់ដំបង	ភូមិទួលខ្វាវ	បារាំងធ្លាក់	ភ្នំព្រឹក	១៨,៩០	១៧,៣០	៥៣២អ	ក្រុមហ៊ុន មរតកភ្នំព្រឹក
		ភូមិសំរោង	អូរដៃល					
		ភូមិពេជ្រចិន្តា	ពេជ្រចិន្តា					
៣	កំពង់ចាម	ភូមិអូរឬស្សី ភូមិអូរប្រឡោះ	អូរម្លូ	ស្ទឹងត្រង់	១,៥២	១,៧៥	៣៥៦អ	លោកស្រី អេង កល្យាន (គម្រោងទី២)
		ភូមិប្រីសមាស ភូមិលេខដប់មួយ ភូមិជាំជ្រៃ ភូមិស្រោងចាន់	ចំការអណ្តូង	ចំការលើ	៣,៩០	១,៧០	២៥៦អ	លោក តែ គឹមសុង (គម្រោងទី៣)
៤	កំពង់ធំ	ភូមិគូ	ចុងជួង	បារាយណ៍	២,៣៥	២,៧៦	០០៦អ	ក្រុមហ៊ុន ផេង គៀង អេឡិកទ្រីស៊ីធី (គម្រោងទី៦)
		ភូមិតាឌុក	បាល្លង្គ					
		ភូមិទួលសង្កែ	កំពង់ថ្ម	សន្ទុក				
		ភូមិជ័យមង្គល	ជ្រាប់					
៥	កំពត	ភូមិខ្ពបុរន ភូមិថ្មី ភូមិកំណប់ ភូមិព្រៃខ្លែ ភូមិត្បែងពក ភូមិស្រែចែង	ស្រែចែង	ជុំគិរី	៩,៥៥	២,៤០	១៩៧អ	សហគ្រាស អេឡិកទ្រីស៊ីធី អង្គរកា * (គម្រោងទី៩)
		ភូមិព្រៃយ៉ាវ	ស្រែក្នុង					
៦	ក្រចេះ	ភូមិកំពង់ព្នៅ ភូមិកោះច្ការ ភូមិកោះរាល ភូមិស្វាយចេក	បាយសំណុំ	សំបូរ	២៨,១០	-	៣៤៦អ	ក្រុមហ៊ុន ជា សុខខេង (គម្រោងទី៦)
		ភូមិចង្កូប ភូមិស្រែត្រែង ភូមិស្រែស្បូវ	ចង្កូប					

		ភូមិកែងប្រាសាទ	ចារថ្មោល					
		ភូមិស្រែឈូក	ប៉ាត្លែ					
		ភូមិក្តិក្លក់ ភូមិអូរត្រែន	ក្បាលដំរី	អូរគ្រៀង សែនជ័យ	-	២១,០០	៣៤៦អ	ក្រុមហ៊ុន ជា សុខខេង (គម្រោងទី៧)
៧	ពោធិ៍សាត់	ភូមិឯកភាព ភូមិកណ្តាល ភូមិសង្គមថ្មី	ថ្មដា	វាលវែង	៥,៦០	៦,២០	៣៩៦អ	លោកស្រី ប៉ែ សុបញ្ញា (គម្រោងទី៣)
		ភូមិក្រពើពីរលើ ភូមិក្រពើពីរក្រោម ភូមិសំឡាញ	ក្រពើពីរ	វាលវែង	១៥,៦០	៨,២០	៤០៤អ	លោក ហេង ចន្ត្រាវី* (គម្រោងទី៤)
៨	សៀមរាប	ភូមិស្រែពោធិ៍	ស្រែណួយ	វ៉ារិន	៨,៧០	១៦,៩០	២៤០អ	ក្រុមហ៊ុន ហ៊ាង គឹមហេង អេចអេស ផៅវ៉ែ * (គម្រោងទី១១)
		ភូមិខ្នារក្រៅ	កន្ធួត	ស្វាយលើ				
		ភូមិខ្នារវាស	ឃុនរាម	បន្ទាយស្រី				
៩	តាកែវ	ភូមិស្រែខ្វាវ	ជាងទង	ត្រាំកក់	១៦,៨៥	៧,៦៥	១៩៧អ	សហគ្រាស អេឡិកទ្រីស៊ីធី អង្គរកា* (គម្រោងទី៩)
		ភូមិម្រុំ ភូមិតាកេម ភូមិតាសូ ភូមិប្រវង់ ភូមិឈើទាល	តាកេម					
		ភូមិសំបូរ ភូមិលីញ ភូមិតាសោម ភូមិតាប៉ែន	សំរោង					
		ភូមិព្រៃតានាម ភូមិត្រពាំងលាន ភូមិគូស ភូមិតា លាក់ខាងត្បូង ភូមិត្រពាំងព្រីង	គូស					
		ភូមិត្រពាំងព្រៃ ភូមិសំរោង	ត្រពាំងធំ ខាងត្បូង					
		ភូមិអង្គត្រាវ	ត្រពាំងធំ ខាងជើង					
		ភូមិត្រពាំង ភូមិស្នឹង ភូមិក្រឡាញ់ ភូមិឆ្នោតជុំ ភូមិសុក្រំ ភូមិទួលខ្ពុង ភូមិដំណាក់ខ្លុង ភូមិត្រពាំងក្ងួ ភូមិឫស្សីមួយគុម្ព	អូរសារ៉ាយ					

		ភូមិត្រពាំងក្រញូង ភូមិត្រពាំងចែង ភូមិព្រៃក្តួច	ត្រពាំង ក្រញូង					
១០	ឧត្តរមានជ័យ	ភូមិនេល	លំទង	អន្លង់វែង	៩,៨០	១,៥០	២៤០អ	ក្រុមហ៊ុន ហ៊ាង គឹម ហេង អេច អេស ផៅរ៉ែ* (គម្រោងទី១១)
		ភូមិអន្លង់វែង	អន្លង់វែង					
		ភូមិទួលគ្រួស	ថ្លាត					
	សរុប I	**៧៧ភូមិ**	**៣៥ឃុំ**	**១៥ស្រុក**	១២១,៩៩	៩១,៥១		
					២១៣,៥០			
ខ. ក្រោមថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់								
១	បាត់ដំបង	ភូមិជ្រោយស្តៅ ភូមិនិគមក្រៅ	ជ្រោយស្តៅ	ថ្មគោល	៣,៧៥	០,៧០	២០១អ	ក្រុមហ៊ុន អគ្គិសនី អ៊ូ ចាន់ត្នែ (គម្រោងទី៥)
		ភូមិតាសី ភូមិសំរោង ភូមិក្រសាំង ភូមិគោកត្រប់	តាម៉ឺន					
២	កំពង់ធំ	ភូមិនីពេជ្រ ក ភូមិនីពេជ្រ ខ	នីពេជ្រ	ប្រាសាទបល្ល័ង្ក	៣,៧០	៤,២០	៣៦៨អ	កញ្ញា តាន់ គឹមបួយ (គម្រោងទី៨)
		ភូមិកប់ប្តុក ភូមិវល្លិ៍យាវ	ដំរីស្លាប់					
		ភូមិក្រយាជើង	ក្រយា					
៣	ព្រះវិហារ	ភូមិពើក	ពទ្រា	ជ័យសែន	៤,៥៤	២,០០	៤០៩អ	លោក អេង សុជាវឌ្ឍនា (គម្រោងទី៣)
៤	ព្រៃវែង	ភូមិដងទុង ភូមិប្រាសាទ ភូមិអំពិល ភូមិថ្កូវ	ប្រាសាទ	កំពង់ត្របែក	២,០១	០,៥០	០៣៦អ	លោកស្រី ពេជ គីម (គម្រោងទី៤)
		ភូមិបន្ទាបបុស្ស	អន្សោង					
៥	ពោធិ៍សាត់	ភូមិក្រាំងរងៀង ភូមិប្រម៉ោយ ភូមិទំព័រ ភូមិស្នឹងថ្មី	ប្រម៉ោយ	វាលវែង	៥,០០	៣,៧០	២៨១អ	លោក វង្ស សំបូរ (គម្រោងទី៦)
		ភូមិសារៀង ភូមិចំរេះ ភូមិតាមោលី ភូមិត្រង់ ភូមិសែនជ័យ ភូមិចំការតាប៉ូ ភូមិក្តីស្វិត ភូមិថ្មី ភូមិព្រីងខ្ពស់ ភូមិផ្ទះព្រីង ភូមិទួលគូ	ស្រែស្តុក	ស្រុកកណ្តៀង	៣,០០	-	៣៨២អ	លោកស្រី គឹម ស៊ីផល (គម្រោងទី៦)

		ភូមិបន្ទាយត្រោក ភូមិផ្ទះកោះ ភូមិវាល ភូមិឆ្លាអំពិល ភូមិគៀន						
		ភូមិកកោះ ភូមិជ្រែង ភូមិសន្លុង	ស្វាយលួង					
		ភូមិកោះដុំ	កោះដុំ					
		ភូមិស្សា	ស្សា					
		ភូមិផ្ទះគរ	អន្លង់វិល					
		ភូមិកណ្តាល ភូមិឆាយលោក ភូមិអូរសោម	អូរសោម	វាលវែង	៧,១០	៣,៦០	៣៩៧អ	លោក ប៉ាវ វុទ្ធា (គម្រោងទី៦)
សរុប ក		**៤៦ភូមិ**	**១៥ឃុំ**	**៧ស្រុក**	**២៩,១០**	**១៤,៧០**	**១៧ អាជ្ញាបណ្ណ**	
					៤៣,៨០			
សរុបរួម ក+ខ		**១២៣ភូមិ**	**៥០ឃុំ**	**២២ស្រុក**	**១៥១,០៩**	**១០៦,២១**		
					២៥៧,៣០			

សំគាល់ៈ តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន២ **តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន៣។



ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្តត់ផ្តង់អគ្គិសនីនៅតំបន់ជនបទក្នុងឆ្នាំ២០២៤

ដំណរភ្ជាប់ដើម្បីចូលទៅកាន់ទីតាំងបែបឌីជីថល

ឧបសម្ព័ន្ធទី៤

ស្តីពីកម្មវិធីឧបត្ថម្ភធនប៉ះប៉ូវបង្ក្រប់ថ្លៃលក់អគ្គិសនីក្នុងឆ្នាំ២០២៤

តារាងទី១ ព័ត៌មានសង្ខេបស្តីពីចំនួនអតិថិជនដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្ក្រប់ថ្លៃលក់អគ្គិសនីជូនអ្នកកាន់អាជ្ញាបណ្ណ

លរ	ខេត្ត/រាជធានី	អតិថិជន						សរុបអតិថិជន
		≤១០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ	១១-៥០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ	៥១-២០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ	>២០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ	សាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាព នៅជនបទ	កសិកម្ម	
១	បន្ទាយមានជ័យ	១៧ ៨៤៣	៤៤ ៩០៣	៣៦ ៩៩៦	៧ ១៥៣	៤១៧	២១	១០៧ ៣៣៣
២	បាត់ដំបង	១៨ ៨៤២	៦១ ៧៧២	៥៨ ១១០	១៤ ៥៨៥	៦២៦	៨០	១៥៤ ០១៥
៣	កំពង់ចាម	២៤ ៩២៤	៨២ ៤៣៣	៦៣ ៦៨៥	១៤ ៥៦៧	៥៣៨	១២៦	១៨៦ ២៧៣
៤	កំពង់ឆ្នាំង	១២ ៣៨៦	៥២ ២៧០	៣៨ ៦៣៥	៩ ០៥១	៣១៨	២៦	១១២ ៦៨៦
៥	កំពង់ស្ពឺ	១៥ ៩៩០	៦២ ៥៧៥	៧៩ ៩៨៨	១៦ ០៨៤	៣៣៦	២១៧	១៧៥ ១៩០
៦	កំពង់ធំ	១៩ ៨៧៤	៦៤ ២៤៨	៣០ ៦៧០	៨ ៦៨៥	៥០៣	៧១	១២៤ ០៥១
៧	កំពត	១៦ ២៣៧	៥១ ២៦៤	៤៤ ៨៨២	៨ ១៦៥	២៧៧	២៦	១២០ ៨៥១
៨	កណ្តាល	៣០ ៧៨៥	៦៦ ០៩៩	៩៨ ៩០២	២៨ ១២២	៣៧៥	៧០	២២៤ ៣៥៣
៩	កោះកុង	២ ២២១	៥ ០៨១	៦ ៦៣៤	៣ ០៥៥	១០១	១	១៧ ០៩៣
១០	ក្រចេះ	៥ ៧៧០	១៧ ២៨០	១៤ ៥២៦	៣ ២២៣	១៧៣	២៧	៤០ ៩៩៩
១១	មណ្ឌលគិរី	០	០	០	៦២	០	០	៦២
១២	ភ្នំពេញ	១ ៤៨២	២ ១៦៣	៤ ៣៦៩	២៨ ៩០២	៧	១	៣៦ ៩២៤
១៣	ព្រះវិហារ	៤ ៦០៨	១៥ ៥៥៦	១០ ៤៥៦	៥ ៧៩១	១៨៨	១	៣៦ ៦០០
១៤	ព្រៃវែង	២៩ ៦៥៦	១០៦ ០៩៤	៧០ ១១៣	១៤ ៤៤៣	៦៥០	១ ៥៩៥	២២២ ៥៥១
១៥	ពោធិ៍សាត់	១៨ ៦៩៤	៤៥ ៥០៩	៣២ ១៥១	១០ ៦៧០	៣៧៧	២៦	១០៣ ៤២៧
១៦	រតនគីរី	៩៨២	៤ ៦២០	៣ ៨៦៥	១ ៩៦៩	១០៤	២	១១ ៥៤២
១៧	សៀមរាប	១៨ ៥០១	៦៧ ៧៩០	៣៧ ០២៥	១០ ៥៦០	៥៥១	៤២	១៣៤ ៤៦៩
១៨	ព្រះសីហនុ	២ ៥៣៣	៥ ៧៥៣	១២ ៥៩០	៧ ៧០៣	៥៤	៩	២៨ ៦៤២
១៩	ស្ទឹងត្រែង	៧៧៩	២ ៣៣៤	២ ១៥៦	៨០០	៣៧	៣	៦ ១០៩
២០	ស្វាយរៀង	៥ ៥២៩	១៨ ៤៥៤	១៣ ៩៦៩	១ ៥០៦	៧៣	២	៣៩ ៥៣៣
២១	តាកែវ	២១ ៣៤១	៧២ ០៩៨	៨៨ ១៣២	១៦ ៦០៨	៤៤៤	១៣៦	១៩៨ ៧៥៩
២២	ឧត្តរមានជ័យ	៤ ៦៣៦	១៤ ៩៣៩	១១ ៣១០	៤ ៣៥៦	២០៣	១	៣៥ ៤៤៥
២៣	កែប	១ ៤២៣	៣ ៧៦០	៦ ៦០៤	២ ៤១៣	៣៨	៦	១៤ ២៤៤
២៤	ប៉ៃលិន	៦៣៤	១ ៨១៦	២ ៩២៧	១ ៨៣២	០	៨	៧ ២១៧
២៥	ត្បូងឃ្មុំ	១៣ ៩៥៧	៦០ ៥២៤	៤៩ ៧២៦	៩ ៨៤២	៤៣១	៣៧	១៣៤ ៥១៧
សរុប		**២៨៥ ៦២៧**	**៩២៩ ៣៣៥**	**៨១៨ ៤២១**	**២៣០ ១៤៧**	**៦ ៨២១**	**២ ៥៣៤**	**២ ២៧២ ៨៨៥**
ភាគរយ		**១២,៥៧%**	**៤០,៨៩%**	**៣៦,០១%**	**១០,១៣%**	**0,៣0%**	**0,១១%**	**១00%**



តារាងទី២ ព័ត៌មានសង្ខេបស្តីពីបរិមាណថាមពលដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធន ប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីជូនអ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៤

លរ	ខេត្តក្រុង	ថាមពលអគ្គិសនី (គីឡូវ៉ាត់ម៉ោង)						សរុបថាមពល (គីឡូវ៉ាត់ម៉ោង)
		≤១០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ	១១-៥០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ	៥១-២០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ	>២០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ	សាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាព នៅជនបទ	កសិកម្ម	
១	បន្ទាយមានជ័យ	៥៨១ ៦៤១	១៤ ១៣៣ ៥៧៦	៤៩ ៣០៤ ៨៩៧	៣៦ ៩១៥ ៩០៥	១ ២២៦ ៦៩២	៣ ៨៥៤ ៤៩៩	១០៦ ០១៧ ២១០
២	បាត់ដំបង	៦៥៥ ៥៨៣	១៩ ៦៧៨ ២៩០	៧៥ ១១៩ ៩២៥	៦៨ ៦៨៧ ០៤៧	១ ៧៩១ ០៤១	១១ ៧៦៦ ៤៣៥	១៧៧ ៦៩៤ ៣២១
៣	កំពង់ចាម	៩៧០ ០៥៤	២៧ ១៩០ ១៧៧	៨១ ០៧០ ២៦៧	៦១ ១៨២ ៤០០	១ ៥៨៨ ៦២៣	៤ ៥៧៣ ៣៧៩	១៧៦ ៥៧៤ ៩០០
៤	កំពង់ឆ្នាំង	៥៣០ ៨៨៤	១៦ ៩១៣ ០៤៥	៤៨ ៨៣០ ៤២៩	៤៤ ១១៦ ៥០១	៧៣៧ ៣១៧	២ ៩២០ ១២៤	១១៤ ០៤៨ ៣០០
៥	កំពង់ស្ពឺ	៥៦១ ៦៩៧	២១ ៦១៣ ៤៣៤	៩៦ ៩១៧ ៧២៥	៧៦ ០៤៤ ២៤៧	១ ០៣៧ ៤៦៨	២៧ ៥៨០ ៧៨១	២២៣ ៧៥៥ ៣៥២
៦	កំពង់ធំ	៧៨៨ ២៥០	២០ ៤៤១ ២២៦	៣៨ ៥១២ ៩១៥	៣២ ៣៤៨ ២២៦	៨៥៥ ០៩៥	៤ ៨៤២ ៤៩៩	៩៧ ៧៨៨ ២១១
៧	កំពត	៦២៣ ៤៨៧	១៧ ០៦៥ ៥៨១	៥៥ ១០៦ ០៤៥	៣៣ ៩៥៦ ៣៨២	៤៨៨ ៤៣២	៤ ២០៧ ៧៣២	១១១ ៤៤៧ ៦១៩
៨	កណ្តាល	៦៩៣ ៤០៩	២១ ៧៩៤ ៧៩៣	១២៥ ៩៦២ ៤៥៧	១៨៧ ៤៨៧ ៣៣០	១ ២៤៧ ០៩០	១ ៨៣៥ ៣៧៣	២៩៩ ០២០ ៤៥២
៩	កោះកុង	៥៣ ២៨៧	១ ៧២៦ ៧៤៨	៨ ៣៩៩ ៨៩៨	១៣ ១៥៧ ២៩៨	២៧១ ៨៧៧	២៩ ៧៧១	២៣ ៦៣៨ ៨៧៩
១០	ក្រចេះ	២១៩ ៨០៩	៥ ៥៥០ ២៤៧	១៨ ៦១០ ៨១៨	១៤ ៧៨៣ ៦០៣	៤៤៨ ៧៥៨	១ ៥៨០ ២៧៦	៤១ ១៩៣ ៥១១
១១	មណ្ឌលគិរី	០	០	០	៤៦ ៧៩១	០	០	៤៦ ៧៩១

១២	ភ្នំពេញ	២៥ ៨៣១	៦៩៦ ៣៧៥	៥ ៥២៨ ០៤០	២៨ ៥៩៤ ៤៣២	៦៩ ៧៧៤	១១៣ ៥៧៦	៣៥ ០២៨ ០២៨
១៣	ព្រះវិហារ	១៦៦ ០១៥	៥ ២៣៤ ០៦១	១៣ ៨៨០ ២៤៧	២៤ ១៦៨ ៣៩៦	៦៦២ ៦២៦	៨ ៣៣២	៤៤ ១១៩ ៦៧៧
១៤	ព្រៃវែង	១ ១០៨ ០៣៨	៣៥ ១៣៥ ៨៣៥	៩០ ៣៩៩ ៨៦៧	៦០ ៥៥២ ០៥៦	២ ១៥១ ៥៨៩	៤ ១៥៥ ៥៩១	១៩៣ ៥០២ ៩៧៦
១៥	ពោធិ៍សាត់	៥៤៥ ៩៥៦	១៤ ៧០៨ ២១៩	៤០ ៧៦៤ ៧០៦	៤៥ ៨៣០ ៧៦៥	១ ១៨៥ ៣១២	២ ៥៤០ ៨៧០	១០៥ ៥៧៥ ៨២៨
១៦	រតនគីរី	៤២ ៦២៧	១ ៤៦៩ ០៤៤	៤ ៩៤៨ ១០៧	៧ ០៧៤ ០២៤	២៤៨ ៨០១	៥១ ៦៦០	១៣ ៨៣៤ ២៦៣
១៧	សៀមរាប	៧៣៩ ៩៩៤	២១ ២៧១ ៧៣១	៥០ ៣៥២ ៩៦៧	៤១ ៥១៥ ៩៣០	១ ៦៩៥ ៥២៩	១ ៤៩៩ ៩២៥	១១៧ ០៧៦ ០៧៦
១៨	ព្រះសីហនុ	៥៩ ៣១៥	២ ១១៤ ៩៨៥	១៥ ៩១៧ ៥៦១	២៧ ៦៩៩ ៤០៥	១៨០ ៤៥១	៤ ៣២៨ ៦៤២	៥០ ៣០០ ៣៥៩
១៩	ស្ទឹងត្រែង	២២ ៨១២	៧១៦ ៧៦១	២ ៨៣៤ ៥៣១	៣ ៩៨៣ ៥០៨	៥១ ៦៥២	១៩៣ ៩៨៣	៧ ៨០៣ ២៤៧
២០	ស្វាយរៀង	១៦៨ ១៥៩	៦ ០៥៩ ០២៧	១៧ ៦៩៧ ៦០០	៧ ០៥៤ ៩៧៣	៣៦៦ ១៦៤	១៥៣ ៤៥៦	៣១ ៤៩៩ ៣៧៩
២១	តាកែវ	៦៨៩ ៤៣៨	២៤ ១៤៦ ២០៩	១១១ ១៦៧ ២៤០	៧២ ២៤៤ ៨៩៩	១ ៤៣៨ ៩៧១	១១ ១៥៣ ៩៩៩	២២០ ៨៤០ ៧៥៦
២២	ឧត្តរមានជ័យ	១៧២ ៣៣១	៤ ៥៧៦ ៦៨១	១៥ ០៤០ ១០៦	២២ ៣៥៨ ៨៧៧	៣៥១ ៩១៩	១ ៣៨៩ ០០០	៤៣ ៨៨៨ ៩១៤
២៣	កែប	៣៦ ០៨១	១ ២៨៤ ៥៥៩	៨ ៤០៧ ៥៣៥	១២ ៣៨១ ៥៤៨	១០២ ៥៦៩	១៩៣ ៦៨៦	២២ ៤០៥ ៩៧៨
២៤	ប៉ៃលិន	១៧ ៨៣៦	៦០០ ៥១១	៣ ៧០៦ ២៦២	៧ ៦៣៥ ៤២៩	០	១ ១៣៦ ៣៥៥	១៣ ០៩៦ ៣៩៣
២៥	ត្បូងឃ្មុំ	៦៦០ ៩១៩	១៩ ៩៦៨ ៩៨៧	៦១ ៥១៦ ១១៥	៤៦ ៨៣៧ ៦៧០	៩១៤ ៩៥៧	៨ ៧៧៩ ៧២៦	១៣៨ ៦៧៨ ៣៧៤
សរុប		**១០ ១៣៣ ៤១៣**	**៣០៤ ០៨៦ ១០២**	**១ ០៣៩ ៩៩៦ ២៦០**	**៩៣៦ ៦៥៧ ៦៤២**	**១៩ ១១២ ៧០៧**	**៩៨ ៨៨៩ ៦៧០**	**២ ៤០៨ ៨៧៥ ៧៩៤**
ភាគរយ		**០,៤២%**	**១២,៦២%**	**៤៣,១៧%**	**៣៨,៨៨%**	**០,៧៩%**	**៤,១១%**	**១០០%**



ឧបសម្ព័ន្ធទី៥

រចាយការណ៍សង្ខេបស្តីពីកម្មវិធីផ្តល់ការអនុគ្រោះពិសេសក្នុងវិស័យកសិកម្មក្នុងឆ្នាំ២០២៤

តារាងទី១ ព័ត៌មានសង្ខេបស្តីពីអតិថិជនបានតភ្ជាប់ចរន្តប្រភេទកសិកម្ម និងទីតាំង

ធ្វើកសិកម្មតាមខេត្តនីមួយៗ ក្នុងឆ្នាំ២០២៤

ក្រោមតំបន់ក្រោមតំបន់អាជ្ញាបណ្ណរបស់អគ្គិសនីកម្ពុជា

ល.រ	អង្គភាពអគ្គិសនីខេត្ត	ចំនួនសៀវភៅ	ចំនួនអតិថិជនកសិកម្ម	ចំនួនអតិថិជនផ្សេងៗប្លែ ឬសុំបន្តថ្មី		ប្រភេទកសិកម្ម
				អតិថិជនប្តូរមកតម្លៃអនុគ្រោះ	អតិថិជនតភ្ជាប់ចរន្តថ្មី	
១	អគ្គិសនីបន្ទាយមានជ័យ	១	៥	៤	-	រោងម៉ាស៊ីនកសិកម្ម
				១	-	ចិញ្ចឹមសត្វ
២	អគ្គិសនីបាត់ដំបង	១	៨	៦	២	រោងម៉ាស៊ីនកសិកម្ម
៣	អគ្គិសនីកំពង់ចាម	១	១	១	-	ដាំដុះ និងចិញ្ចឹមសត្វ
៤	អគ្គិសនីកំពង់ស្ពឺ	១	៧	៣	១	ចិញ្ចឹមសត្វ
				២	១	រោងម៉ាស៊ីនកសិកម្ម
៥	អគ្គិសនីកំពត	១	២៨	១២	១៦	ដាំដុះ
៦	អគ្គិសនីក្រចេះ	១	៣	១	-	រោងម៉ាស៊ីនកសិកម្ម
				២	-	ចិញ្ចឹមសត្វ និងដាំដុះ
៧	អគ្គិសនីមណ្ឌលគិរី	១	១	-	១	ដាំដុះ
៨	អគ្គិសនីព្រៃវែង	១	៤២	១	៤១	ដាំដុះ
៩	អគ្គិសនីសៀមរាប	១	៧	៥	១	ដាំដុះ
				១	-	រោងម៉ាស៊ីនកសិកម្ម
១០	អគ្គិសនីស្វាយរៀង	១	២	២	-	ដាំដុះ
១១	អគ្គិសនីតាកែវ	១	២	២	-	ចិញ្ចឹមសត្វ
១២	អគ្គិសនីត្បូងឃ្មុំ	១	៧	៦	១	ដាំដុះ
សរុប		**១២**	**១១៣**	**៤៩**	**៦៤**	

សំគាល់៖ អតិថិជនទាំងអស់ស្ថិតនៅក្រោមតំបន់អាជ្ញាបណ្ណរបស់អគ្គិសនីកម្ពុជាតែមួយ។

<u>តារាងទី២</u> ព័ត៌មានសង្ខេបស្តីពីអតិថិជនបានតភ្ជាប់ចរន្តប្រភេទកសិកម្ម និងទីតាំងធ្វើកសិកម្មតាមខេត្តនីមួយៗ ក្រោមតំបន់អ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៤

ល.រ	ខេត្ត	អ្នកកាន់អាជ្ញាបណ្ណ	លេខ អ.ប	ចំនួនអតិថិជនកសិកម្ម	ចំនួនអតិថិជន		ប្រភេទកសិកម្ម
					អតិថិជនប្តូរតម្លៃអនុគ្រោះ	អតិថិជនតភ្ជាប់ចរន្តថ្មី	
១	បន្ទាយមានជ័យ	ក្រុមហ៊ុន ជីអិមភីអ ត្រេឌីង ឯ.ក	៣៥១អ	១	១	-	ដាំដុះ
		ក្រុមហ៊ុន ជី អិន អិន ជី អេឡិកទ្រីស៊ីធី	១០៥អ	២	២	-	រោងម៉ាស៊ីន
២	បាត់ដំបង	ក្រុមហ៊ុន អេសវី អេឡិកទ្រីស៊ីធី	០៤៣អ	១	-	១	រោងម៉ាស៊ីន
		លោក ណុប ប៊ិន	០៦៩អ	៣	២	-	រោងម៉ាស៊ីន
					១	-	ដាំដុះ
		លោកស្រី សាន់ ឆាន់	២៤២អ	១	-	១	ដាំដុះ
		ក្រុមហ៊ុន ខេ.អ.វ៉ាយ ត្រេឌីង	២៤៤អ	៤	១	៣	ដាំដុះ
		ក្រុមហ៊ុន អេឡិចទ្រិចខល អូតាគី អ៊ី.អូ.ធី ត្រេឌីង	២៧០អ	១	១	-	ចិញ្ចឹមសត្វ
		ក្រុមហ៊ុន អេស.ខេ.ភី.អិន.ខេ អ៊ិនវេសម៊ិន	៤០៣អ	២	១	-	រោងម៉ាស៊ីន
					-	១	ដាំដុះ
៣	កំពង់ចាម	ក្រុមហ៊ុន មេគង្គ ស្មាត ផៅវ៉ែ	០២៣អ	២	១	-	រោងម៉ាស៊ីន
					១	-	ចិញ្ចឹមសត្វ
		សហគ្រាសអគ្គិសនី សុហ៊ីន	០៥៧អ	១	-	១	ដាំដុះ
		សហគ្រាស អេឡិកទ្រីស៊ីធី ទ្រី ឡេង	១៣០អ	៥	-	៤	ដាំដុះ
					-	១	ចិញ្ចឹមសត្វ
		ក្រុមហ៊ុន អគ្គិសនី ព្រែកពោធិ៍	១៦០អ	១	-	១	ដាំដុះ
		សហគ្រាស អេឡិចទ្រីស៊ីធី ស្តន់-ចំការលើ	២២០អ	១	១	-	ចិញ្ចឹមសត្វ
		លោកស្រី សោម សុខាលីន	២៥៥អ	៣៩	១៨	២១	ដាំដុះ
		លោក សេង គ្រី	២៩២អ	១	-	១	ដាំដុះ
		សហគ្រាស វ៉ាត ណារុណ	៣៩៤អ	២	-	២	រោងម៉ាស៊ីន
៤	កំពង់ឆ្នាំង	លោក អ៊ុន សុធា	១១៩អ	៤	៤	-	ចិញ្ចឹមសត្វ
		ក្រុមហ៊ុន អូ អេស វី អ ត្រេឌីង	៣០០អ	២	១	-	ចិញ្ចឹមសត្វ
					១	-	ដាំដុះ
		សហគ្រាស អេន ចន្ថា អេឡិកទ្រីស៊ីធី	៤២៩អ	៣	៣	-	ចិញ្ចឹមសត្វ
៥	កំពង់ស្ពឺ	សហគ្រាស ឧដុង្គ ផៅវ៉ែ សឹបផ្លាយ	០៧៦អ	១	១	-	ចិញ្ចឹមសត្វ
		សហគ្រាស អគ្គិសនី ពេជ្រនិល អិល.អេស.ខេ	០៨២អ	៤	៤	-	ចិញ្ចឹមសត្វ
		ក្រុមហ៊ុន លីមម៉ូវ ខូអិលធីឌី	០៩៩អ	៤	៤	-	ចិញ្ចឹមសត្វ

		ក្រុមហ៊ុន តូវ ឈិនសេង ខូអិលធីឌី	១០១អ	៤	៤	-	ចិញ្ចឹមសត្វ
		ក្រុមហ៊ុន ម៉េង សុខឡេង ខនស្ត្រាក់សិន	១៣៧អ	១	១	-	ចិញ្ចឹមសត្វ
		សហគ្រាស អភិវឌ្ឍន៍អគ្គិសនី សំរិទ្ធិគីរី	១៥៥អ	៧	៥	២	ចិញ្ចឹមសត្វ
		ក្រុមហ៊ុន ភ្នំពេញ ស៊ូហ្គឺរ អេឡិកទ្រីស៊ីធី	៣៣៨អ	៣	៣	-	ចិញ្ចឹមសត្វ
		ក្រុមហ៊ុន ចាន់ គឹមអេង អេឡិកទ្រីស៊ីធី	៣៨៥អ	១	-	១	ចិញ្ចឹមសត្វ
		ក្រុមហ៊ុន បសេដ្ឋ អេឡិកទ្រីស៊ីធី	៣៨៦អ	១	១	-	ចិញ្ចឹមសត្វ
		ក្រុមហ៊ុន រុងរឿង អេឡិចទ្រីស៊ីធី	៣៩៣អ	៤	៤	-	ចិញ្ចឹមសត្វ
៦	កំពង់ធំ	ក្រុមហ៊ុន ផេង គៀង អេឡិកទ្រីស៊ីធី	០០៦អ	៤	-	៤	ដាំដុះ
		សហគ្រាស រ៉ាស័ង អេឡិកទ្រីស៊ីធី ផៅវ៉ែ	០៣៩អ	៥	-	៥	ដាំដុះ
		សហគ្រាស ត្រឹង សាន	០៧៣អ	៤	៣	-	ដាំដុះ
					១	-	ចិញ្ចឹមសត្វ
		សហគ្រាស ឈា សុខុម	២៤៥អ	៧	-	៧	ដាំដុះ
		លោក ខុន ចិត្រា	៣២៧អ	១	១	-	ចិញ្ចឹមសត្វ
		លោក សៀង ទី	៣២៨អ	១	១	-	ដាំដុះ
		សហគ្រាស អេច.ធី.អ.ធី អេឡិកទ្រីស៊ីធី	៣៨៧អ	២	១	-	ដាំដុះ
					-	១	រោងម៉ាស៊ីន
		លោក ថេង សំរិទ្ធ	៤៤០អ	១	១	-	ដាំដុះ
៧	កំពត	ក្រុមហ៊ុន អគ្គិសនី ទឹកឈូ	០៤៤អ	៣	៣	-	ចិញ្ចឹមសត្វ
		សហគ្រាសអគ្គិសនី ដងទង់	២២៥អ	១	១	-	ចិញ្ចឹមសត្វ
៨	កណ្តាល	លោក សុខ សម្បូរណ៍ *	០៤៥អ	១	-	១	ដាំដុះ
		សហគ្រាស អ៊ិុសធើន ផៅវ៉ែ សឹបផ្លាយ អេនធើប្រាយ	០៤៩អ	២	១	-	ដាំដុះ
					-	១	ចិញ្ចឹមសត្វ
		ក្រុមហ៊ុន លីមម៉ូវ ខូ អិលធីឌី	០៩៩អ	២	១	១	ចិញ្ចឹមសត្វ
		សហគ្រាស អេស អេ អេស អេច អេឡិកទ្រីស៊ីធី ឯ.ក	១៧០អ	៥	៥	-	ចិញ្ចឹមសត្វ
		ក្រុមហ៊ុន ស៊ុន អូន អេឡិចទ្រីស៊ីធី ឯ.ក	១៨៦អ	៥	២	-	ចិញ្ចឹមសត្វ
					-	៣	ដាំដុះ
		សហគ្រាស ព្រែកអំពិលពុកឫស្សី អេឡិកទ្រីស៊ីធី	២០៩អ	២	២	-	រោងម៉ាស៊ីន
		ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី	២២៤អ	១	១	-	ដាំដុះ
		ក្រុមហ៊ុន អគ្គិសនី ជ្រៃលាស់ ឯ.ក	២៧៨អ	៣	៣	-	ចិញ្ចឹមសត្វ
៩	ក្រចេះ	ក្រុមហ៊ុន អេឡិចទ្រីស៊ីធី ខេ៣	៣៥២អ	១៧	១៧	-	ដាំដុះ
១០	ព្រះវិហារ	ក្រុមហ៊ុន ប៊ីវីស៊ី ផៅវ៉ែ ឌីវេឡុបមេន	៣១៥អ	១	១	-	រោងម៉ាស៊ីន

១១	ព្រៃវែង	ក្រុមហ៊ុន អេចខេអេសកី អេឡិចទ្រីស៊ីធី ឯ.ក	០១៨អ	៤៨	៨	៤០	ដាំដុះ
		លោក សុខ សម្បូរណ៍	០៤៥អ	៤៤	២	១	ចិញ្ចឹមសត្វ
					១១	២៩	ដាំដុះ
		សហគ្រាស សុគន្ធ អេឡិកទ្រីខល	០៤៦អ	៧	១	៣	ដាំដុះ
					២	-	រោងម៉ាស៊ីន
					១	-	ចិញ្ចឹមសត្វ
		លោក ខឹម វ៉ានី	១៨៧អ	១	១	-	ដាំដុះ
		ក្រុមហ៊ុន ភី អេស ភី ស៊ី អ៊ិនវេសមេន	២០៦អ	៤	៣	-	ដាំដុះ
					១	-	ចិញ្ចឹមសត្វ
		ក្រុមហ៊ុន អ៊ិនធើ ប៊ីកឺ សឺលូសិន ខបភើរេសិន	២៥៩អ	៦	៥	១	ដាំដុះ
		សហគ្រាស អគ្គិសនី នៅ សុភា	២៦៧អ	១	-	១	ចិញ្ចឹមសត្វ
		សហគ្រាស អគ្គិសនី ឡុង ហៃ	២៨៤អ	៤៥	២០	២៥	ដាំដុះ
		លោកស្រី កែវ ចិន្តា	២៩៤អ	២៣	៤	១៩	ដាំដុះ
		សាខាក្រុមហ៊ុន សាន់-អ៊ីអ៊ីអ៊ី កីធីអ៊ី អិលធីឌី	២៩៥អ	៩	៨	១	ដាំដុះ
		សហគ្រាស អេឡិកទ្រីស៊ីធី អែ លីហួរ	២៩៩អ	៧	២	៥	ដាំដុះ
		លោក ហ៊ាង ផល្លី	៣៣៦អ	១២៨	១៣	១១៥	ដាំដុះ
		ក្រុមហ៊ុន ព្យ៉ែម ហានអេឡិកទ្រីកខល	៣៤៣អ	៣	១	២	ដាំដុះ
		សហគ្រាស ឈរ វ៉ែងង្ហួន អេឡិកទ្រីស៊ីធី អេនធើប្រាយ	៣៥៥អ	៨០២	១៤៤	៦៥៨	ដាំដុះ
		សហគ្រាស អគ្គិសនី ជា សុការីន	៤១៩អ	១	-	១	ដាំដុះ
		សហគ្រាស អគ្គិសនី ព្រៃកណ្តៀង	៤២០អ	៤៧	១	៤៥	ដាំដុះ
					១	-	រោងម៉ាស៊ីន
		ក្រុមហ៊ុន ព្រៃវែង ហាម៉ឺនី ផាតនើរ អេឡិកទ្រីស៊ីធី ឯ.ក	៥៤០អ	៤	-	៤	ដាំដុះ
១២	ពោធិ៍សាត់	សហគ្រាស យេន យូឡាយ អេឡិកទ្រីស៊ីធី	០៣៤អ	១	១	-	ដាំដុះ
		សហគ្រាស ណារ៉េត លីមីធីត អភិវឌ្ឍន៍អគ្គិសនី	០៥២អ	១	-	១	ដាំដុះ
		ក្រុមហ៊ុន ឃឹម ហៀង អេឡិចទ្រីស៊ីធី សឹបផ្លាយ ឯ.ក	៣៨៣អ	១	១	-	ចិញ្ចឹមសត្វ
១៣	រតនគិរី	ក្រុមហ៊ុន អូរយ៉ោដាវ អេឡិកទ្រីស៊ីធី	៣៣៣អ	១	១		ដាំដុះ
១៤	សៀមរាប	ក្រុមហ៊ុន វ៉ន វីរៈ សីវីស	០៣៥អ	១	១	-	ចិញ្ចឹមសត្វ
		សហគ្រាស អគ្គិសនី មាស គាវ	១៨៣អ	២	១	-	ចិញ្ចឹមសត្វ
					១	-	ដាំដុះ

		ក្រុមហ៊ុន ឡោក វណ្ណៈ ឯ.ក	១៨៥អ	២	-	២	ចិញ្ចឹមសត្វ
១៥	ព្រះសីហនុ	លោក ឃុន ចាន់ធារិទ្ធិ	២៧៩អ	២	១	-	ដាំដុះ
					-	១	រោងម៉ាស៊ីន
១៦	តាកែវ	សហគ្រាស គង់ ផាត អេឡិកទ្រីស៊ីធី	០២២អ	២	-	២	ដាំដុះ
		សហគ្រាស អេឡិកទ្រីស៊ីធី សៃវ៉ា	០៥៤អ	១	១	-	ចិញ្ចឹមសត្វ
		ក្រុមហ៊ុន តូវ ឈិនសេង ខូអិលធីឌី	១០១អ	១	-	១	ចិញ្ចឹមសត្វ
		សហគ្រាស អេឡិកទ្រីស៊ីធី ពត់ សរ	១៧៤អ	៤	៤	-	ចិញ្ចឹមសត្វ និងដាំដុះ
		លោក រ៉ូវ ទ្រហ៊ួត	១៩៤អ	២	-	២	ដាំដុះ
		លោក អ៊ូច គា	១៩៥អ	២	២	-	ដាំដុះ
		សហគ្រាស អេឡិកទ្រីស៊ីធី កណ្តឹង	១៩៦អ	១	១	-	ចិញ្ចឹមសត្វ
		សហគ្រាស អេឡិកទ្រីស៊ីធី អង្គរកោ	១៩៧អ	៣	-	៣	ចិញ្ចឹមសត្វ
		សហគ្រាស អគ្គិសនី អិន អិម ក្តាញ់	២១២អ	១	១	-	រោងម៉ាស៊ីន
១៧	ឧត្តរមានជ័យ	ក្រុមហ៊ុន ហ៊ាង គឹមហេង អេចអេស ផៅវ៉ែ ឯ.ក	២៤០អ	២	២	-	ដាំដុះ
១៨	កែប	ក្រុមហ៊ុន កែប ផៅវ៉ែ សឹបផ្លាយ	១៨០អ	២	១	-	ដាំដុះ
					១	-	ចិញ្ចឹមសត្វ
១៩	ប៉ៃលិន	ក្រុមហ៊ុន វណ្ណៈភាព ឌីវេឡុបមេន	០៨៩អ	២	១	-	ដាំដុះ
					១	-	ចិញ្ចឹមសត្វ
២០	ត្បូងឃ្មុំ	ក្រុមហ៊ុន អ៊ី ឌី ខន	១២២អ	៣	២	-	រោងម៉ាស៊ីន
					-	១	ដាំដុះ
សរុប				**១ ៣៩០**	**៣៦៤**	**១ ០២៦**	

សំគាល់៖ -* តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន២

-** តំបន់ធ្វើសេវាកម្មស្ថិតក្នុងខេត្តចំនួន៣

-ដំណរភ្ជាប់ ដើម្បីចូលទៅកាន់ទីតាំង បែបឌីជីថល

អគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦
ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
គេហទំព័រ www.ref.gov.kh